ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ០២ បប

# បទបញ្ជា
## ស្តីពី
## ការដាក់ចេញវិធានការហាមឃាត់ការនាំចូល ការចែកចាយ ការលក់ ការផ្សាយពាណិជ្ជកម្ម ការប្រើប្រាស់ ការកាន់កាប់ ការផលិត និងការស្តុកទុកឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្ហា

អនុលោមតាមយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នីតិកាលទី៧នៃរដ្ឋសភា ក្នុងការអភិវឌ្ឍមូលធនមនុស្សឱ្យមានគុណភាពខ្ពស់និងសុខភាពល្អ ដែលជាទ្រព្យសកម្មជាតិដ៏រឹងមាំសម្រាប់បង្កើនតម្លៃសេដ្ឋកិច្ច លើកកម្ពស់តម្លៃវប្បធម៌ និងបង្កើតគំនិតថ្មីៗ សំដៅធានាចីរភាពកំណើនរយៈពេលវែង និងជីវភាពនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ច។ ក្នុងរយៈពេលថ្មីៗនេះ រាជរដ្ឋាភិបាលបានសង្កេតឃើញថា មានការរីករាលដាលការប្រើប្រាស់ឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្ហា ក្នុងចំណោមកុមារនិងយុវជននៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលផ្តល់ផលប៉ះពាល់យ៉ាងខ្លាំងដល់សណ្តាប់ធ្នាប់សង្គម សុខភាពសាធារណៈ ជាពិសេសសុខភាពរបស់អ្នកសិក្សានិងបុគ្គលិកអប់រំ។ ទន្ទឹមនេះ ការប្រើប្រាស់ផលិតផលទាំងនេះអាចជាច្រកផ្លូវទៅកាន់ការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ផ្សេងទៀត ព្រោះប្រភេទឧបករណ៍អេឡិចត្រូនិកដូចជាបារីអេឡិចត្រូនិក ផលិតផល អេចឈ៍ ធី ភី អាចប្រើសម្រាប់ជក់គ្រឿងញៀនផ្សេងទៀតបាន ព្រមទាំងជាច្រកផ្លូវដែលនាំឱ្យកុមារនិងយុវជនឈានទៅជក់បារីធម្មតាផងដែរ នៅពេលដែលពួកគេមានភាពញៀននឹងសារជាតុនីកូទីន ដែលជាកត្តានាំដល់កំណើននៃជំងឺមិនឆ្លងនៅក្នុងសង្គម។

ក្នុងគោលបំណងទប់ស្កាត់ បង្ការ ដោះស្រាយបញ្ហាឱ្យបានទាន់ពេលវេលា និងដើម្បីរក្សាសណ្តាប់ធ្នាប់សង្គម ការពារសុខភាពសាធារណៈ ជាពិសេសសុខភាពរបស់អ្នកសិក្សានិងបុគ្គលិកអប់រំ រាជរដ្ឋាភិបាលដាក់ចេញបទបញ្ជាដូចខាងក្រោម៖

១- ហាមឃាត់ការនាំចូល ការចែកចាយ ការលក់ ការផ្សាយពាណិជ្ជកម្ម ការប្រើប្រាស់ ការកាន់កាប់ ការផលិត និងការស្តុកទុកឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្ហាគ្រប់ប្រភេទ គ្រប់ទម្រង់ និងគ្រប់មធ្យោបាយ។

២- ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម ក្រសួងព័ត៌មាន និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ត្រូវមានវិធានការទប់ស្កាត់ការនាំចូល ការចែកចាយ ការផ្សាយពាណិជ្ជកម្ម ការលក់ និងការស្តុកទុកឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្ហា។

៣- ក្រសួងសុខាភិបាល ត្រូវចេញសេចក្តីណែនាំ ដើម្បីអប់រំផ្សព្វផ្សាយអំពីផលប៉ះពាល់សុខភាពនិងគ្រោះថ្នាក់នៃការប្រើប្រាស់ឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្ហា។

៤- ក្រសួងអប់រំ យុវជន និងកីឡា ត្រូវចេញសេចក្ដីណែនាំ ដើម្បីអប់រំ បង្ការ ទប់ស្កាត់ និងហាមឃាត់ដាច់ខាតការប្រើប្រាស់ឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្សា នៅក្នុងនិងជុំវិញបរិវេណគ្រឹះស្ថានសិក្សាសាធារណៈ គ្រឹះស្ថានសិក្សាឯកជន គ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀន អន្តេវាសិកដ្ឋាន មជ្ឈមណ្ឌលសិក្សាសហគមន៍ កន្លែងហាត់ប្រាណ កន្លែងលេងកីឡា កន្លែងហ្វឹកហាត់កីឡា និងកន្លែងប្រកួតកីឡា។

៥- គ្រប់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវចាត់វិធានការផ្សព្វផ្សាយ អប់រំ បង្ការ ទប់ស្កាត់ការនាំចូល ការចែកចាយ ការលក់ ការផ្សាយពាណិជ្ជកម្ម ការប្រើប្រាស់ ការកាន់កាប់ ការផលិត និងការស្តុកទុកឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្សា នៅតាមមូលដ្ឋានស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

៦- គ្រប់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបង្កើនការត្រួតពិនិត្យជាប្រចាំ ហាមឃាត់ចំពោះមន្ត្រីរាជការស៊ីវិល មន្ត្រីនគរបាលជាតិ និងយោធិន ព្រមទាំងមន្ត្រីជាប់កិច្ចសន្យាដែលស្ថិតក្រោមឱវាទរបស់ខ្លួនលើការប្រើប្រាស់ឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្សា ឬមានការពាក់ព័ន្ធនឹងឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្សានេះ។

៧- គ្រប់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវចាត់វិធានការចំពោះបុគ្គលណាដែលប្រើប្រាស់ និង/ឬកាន់កាប់ឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្សាគ្រប់ប្រភេទ និងត្រូវព្រមានដោយផ្ទាល់មាត់ ព្រមទាំងដកហូតឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្សា។ ករណីមិនរាងចាល ត្រូវព្រមានជាលាយលក្ខណ៍អក្សរ និងធ្វើកិច្ចសន្យាឈប់ប្រើប្រាស់។

៨- គ្រប់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវចាត់វិធានការស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមានចំពោះបុគ្គលណាដែលបានចែកចាយ លក់ ស្តុកទុក ផ្សព្វផ្សាយពាណិជ្ជកម្មឬផ្សព្វផ្សាយលក់ផលិត និង/ឬនាំចូលឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្សា តាមមធ្យោបាយណាក៏ដោយ ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដកហូត និងព្យួរវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្ម អាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្មដែលចេញដោយក្រសួង ស្ថាប័ន ឬអាជ្ញាធរពាក់ព័ន្ធ ទោះជាប្រភេទអាជីវកម្ម សេវាកម្មអ្វីក៏ដោយ។

៩- គ្រប់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវចាត់វិធានការដាក់ទណ្ឌកម្មរដ្ឋបាលចំពោះមន្ត្រីរាជការស៊ីវិល មន្ត្រីនគរបាលជាតិ និងយោធិន ព្រមទាំងមន្ត្រីជាប់កិច្ចសន្យាដែលស្ថិតក្រោមឱវាទរបស់ខ្លួនលើការប្រើប្រាស់ឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្សា ឬមានការពាក់ព័ន្ធនឹងឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្សា។

គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវអនុវត្តបទបញ្ជានេះឱ្យបានម៉ឺងម៉ាត់បំផុតនិងមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃអង្គារ ១៤រោច ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែ តុលា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ទីស្តីការគណៈរដ្ឋមន្ត្រី**

ខុទ្ទកាល័យសម្តេចធិបតីនាយករដ្ឋមន្ត្រី
(វិមានសន្តិភាព)
ចូល លេខ: 2779
ថ្ងៃទី: 13 ...2025
ម៉ោង: 10h00 Am

**សូមគោរពជូន**
**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**
**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ ៖** ករណីសំណើសុំការពិនិត្យនិងសម្រេចលើសេចក្តីព្រាងបទបញ្ជារបស់រាជរដ្ឋាភិបាល ស្តីពីការដាក់ចេញវិធានការហាមឃាត់ការនាំចូល ការចែកចាយ ការលក់ ការផ្សាយពាណិជ្ជកម្ម ការប្រើប្រាស់ ការកាន់កាប់ ការផលិត និងការស្តុកទុកឧបករណ៍អេឡិចត្រូនិកនិងសារជាតុគីមីសម្រាប់ជក់ និងស៊ីស្យា។

**យោង ៖** - លិខិតលេខ៣២០២ អយក.សស ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៥ របស់ក្រសួងអប់រំ យុវជន និងកីឡា
- របាយការណ៍លេខ១៥ របក.អវ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៥ ស្តីពីលទ្ធផលនៃកិច្ចប្រជុំជំនាញបច្ចេកទេសនៅទីស្តីការគណៈរដ្ឋមន្ត្រី
- របាយការណ៍លេខ៥៣ របក.អក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៥ ស្តីពីលទ្ធផលនៃកិច្ចប្រជុំអន្តរក្រសួងចង្អៀតនៅទីស្តីការគណៈរដ្ឋមន្ត្រី។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសុខាភិបាល បានសហការរៀបចំ "សេចក្តីព្រាងបទបញ្ជារបស់រាជរដ្ឋាភិបាល ស្តីពីការដាក់ចេញវិធានការហាមឃាត់ការនាំចូល ការចែកចាយ ការលក់ ការផ្សាយពាណិជ្ជកម្ម ការប្រើប្រាស់ ការកាន់កាប់ ការផលិត និងការស្តុកទុកឧបករណ៍អេឡិចត្រូនិកនិងសារជាតុគីមីសម្រាប់ជក់ និងស៊ីស្យា" ក្នុងគោលបំណងចូលរួមទប់ស្កាត់ បង្ការ និងដោះស្រាយឱ្យបានទាន់ពេលវេលានូវបញ្ហាដែលបណ្តាលមកពីការប្រើប្រាស់ឧបករណ៍អេឡិចត្រូនិកនិងសារជាតុគីមីសម្រាប់ជក់ និងស៊ីស្យា ដែលកំពុងតែរីករាលដាលក្នុងចំណោមកុមារនិងយុវវ័យកម្ពុជា និងដើម្បីរួមចំណែករក្សាសណ្តាប់ធ្នាប់សង្គម ការពារសុខភាពសាធារណៈ ពិសេសសុខភាពរបស់អ្នកសិក្សានិងបុគ្គលិកអប់រំ។

ខ្ញុំបាទសូមគោរពជម្រាបជូន **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា ឯកសារសេចក្តីព្រាងបទបញ្ជារបស់រាជរដ្ឋាភិបាលខាងលើនេះ ត្រូវបានសាមីក្រសួងរៀបចំតាក់តែងឡើងដំបូងក្នុងទម្រង់ជា **អនុក្រឹត្យ** ដែលបានដាក់ឆ្លងកិច្ចប្រជុំជំនាញបច្ចេកទេសនៅទីស្តីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២៥។ ដោយពិនិត្យឃើញថា ការរៀបចំក្នុងទម្រង់ជាអនុក្រឹត្យ អាចមានអនីត្យានុកូលភាពទៅនឹងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ជាអាទិ៍ ច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់(ឆ្នាំ២០១៥) ព្រមទាំងក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ ក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រីបានលើកឡើងនូវជម្រើសកែសម្រួលចំនួនពីរគឺ: ទី១-រៀបចំជាបទបញ្ជារបស់រាជរដ្ឋាភិបាល (*ជម្រើសនេះជាវិធានការបន្ទាន់ និងអាចឆ្លើយតបនឹងតម្រូវការដាក់ស្តែង ក៏ប៉ុន្តែមានលក្ខណៈបណ្តោះអាសន្ន*) និង ទី២-ធ្វើវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់ ឬរៀបចំជាសេចក្តីព្រាងច្បាប់ថ្មីតែម្តង (*ជម្រើសនេះជាវិធានការដែលទាមទារការគិតគូរឱ្យបានគ្រប់ជ្រុងជ្រោយនិងអាចចំណាយរយៈពេលវែងដើម្បីរៀបចំ ក៏ប៉ុន្តែនឹងផ្តល់នូវដំណោះស្រាយរយៈពេលវែង*)។ ជាលទ្ធផល សាមីក្រសួងទាំងពីរបានឯកភាពនិងកែសម្រួលទៅជា **សេចក្តីព្រាងបទបញ្ជារបស់រាជរដ្ឋាភិបាល** ដោយផ្អែកលើតម្រូវការដាក់ស្តែងនិងស្ថានភាពបន្ទាន់លើការគ្រប់គ្រងផលិតផលថ្នាំជក់ទម្រង់ថ្មីនេះ ឱ្យស្របនឹងនិន្នាការវិវត្តនៃកត្តាសេដ្ឋកិច្ច-សង្គមនាពេលបច្ចុប្បន្ន។

សេចក្តីព្រាងបទបញ្ជាខាងលើនេះ ត្រូវបានបន្តដាក់ឆ្លងក្នុងកិច្ចប្រជុំអន្តរក្រសួងចង្អៀត នៅទីស្តីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២៥ ដោយបានពិនិត្យនិងកែសម្រួលលើពាក្យពេចន៍និងខ្លឹមសារមួយចំនួន ដូចមានអត្ថបទគោរពជូនភ្ជាប់។

យោបល់ទីស្តីការគណៈរដ្ឋមន្ត្រី៖

- គួរឯកភាពតាមសំណើរបស់ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសុខាភិបាល លើសេចក្តីព្រាងបទបញ្ជារបស់រាជរដ្ឋាភិបាល ស្តីពីការដាក់ចេញវិធានការហាមឃាត់ការនាំចូល ការចែកចាយ ការលក់ ការផ្សាយពាណិជ្ជកម្ម ការប្រើប្រាស់ ការកាន់កាប់ ការផលិត និងការស្តុកទុកឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្សា ដើម្បីដាក់ចេញនូវវិធានការបន្ទាន់និងចាំបាច់(ជាបណ្តោះអាសន្ន) ក្នុងការដោះស្រាយបញ្ហាប្រឈមចំពោះមុខ និងទប់ស្កាត់ការប្រើប្រាស់ឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្សា ដែលកំពុងតែរីករាលដាលនាពេលបច្ចុប្បន្ន
- ជាជំហានបន្ទាប់ គួរពិនិត្យលទ្ធភាពដ៏ខ្ពង់ខ្ពស់ អនុញ្ញាតជាគោលការណ៍ឱ្យក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសុខាភិបាល សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ សិក្សាលើជម្រើសនៃការធ្វើវិសោធនកម្មច្បាប់ស្តីការត្រួតពិនិត្យផលិតផលថ្នាំជក់(ឆ្នាំ២០១៥) ឬជម្រើសនៃការរៀបចំជាសេចក្តីព្រាងច្បាប់ថ្មីតែម្តង ដើម្បីធ្វើការគ្រប់គ្រងលើផលិតផលថ្នាំជក់ ព្រមទាំងឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្សា និងផលិតផលថ្នាំជក់ទម្រង់ថ្មីៗទៀត ឱ្យបានគ្រប់ជ្រុងជ្រោយ រួចគោរពរាយការណ៍ជូន សម្តេចធិបតីនាយករដ្ឋមន្ត្រី ដើម្បីពិនិត្យនិងសម្រេចដ៏ខ្ពង់ខ្ពស់។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មេត្តាពិនិត្យ សម្រេច និងគោរពសុំមតិដឹកនាំដ៏ខ្ពង់ខ្ពស់។

ដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់បំផុត

ថ្ងៃ ៣ ៨ ៤ រោច ខែ ស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**

14.08.25

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

លេខ ៥៣ ពណក.ររក

ថ្ងៃសុក្រ ៤ រោច ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៥

# របាយការណ៍ស្តីពី
# លទ្ធផលនៃកិច្ចប្រជុំអន្តរក្រសួងចង្អៀត ពិនិត្យ ពិភាក្សាលើសេចក្តីព្រាងនៃបទបញ្ជាស្តីពីការដាក់ចេញវិធានការហាមឃាត់ការនាំចូល ការចែកចាយ ការលក់ ការផ្សាយពាណិជ្ជកម្ម ការប្រើប្រាស់ ការកាន់កាប់ ការផលិត និងការស្តុកទុកឧបករណ៍អេឡិចត្រូនិក និងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្សា

កាលពីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២៥ វេលាម៉ោង ៨:៣០នាទីព្រឹក នៅទីស្តីការគណៈរដ្ឋមន្ត្រី (អគារភាតរភាព) បន្ទប់ ៧-០៨ មានបើកកិច្ចប្រជុំអន្តរក្រសួងចង្អៀត ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត ស៊ា ម៉ៅ រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី អនុប្រធាន និងជាអគ្គលេខាធិការនៃក្រុមប្រឹក្សាអ្នកច្បាប់ ដើម្បីពិនិត្យនិងពិភាក្សាលើសេចក្តីព្រាងនៃបទបញ្ជាស្តីពីការដាក់ចេញវិធានការហាមឃាត់ការនាំចូល ការចែកចាយ ការលក់ ការផ្សាយពាណិជ្ជកម្មការប្រើប្រាស់ ការកាន់កាប់ ការផលិត និងការស្តុកទុកឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្សា ដោយចៀសវាងភាពខ្វាស់ទៅនឹងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលដែលធ្លាប់ចេញកន្លងមក។

កិច្ចប្រជុំមានការអញ្ជើញចូលរួមពីឯកឧត្តម **អ៊ីន វីរជាតិ** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី លោកជំទាវ **គីម សេដ្ឋានី** រដ្ឋលេខាធិការប្រចាំការក្រសួងអប់រំ យុវជន និងកីឡា ឯកឧត្តម **ឃឹត ស៊ីនណារ៉ា** រដ្ឋលេខាធិការក្រសួងសុខាភិបាល និងឯកឧត្តម លោកជំទាវ តំណាងក្រសួងមហាផ្ទៃ ក្រសួងពាណិជ្ជកម្ម ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រសួងព័ត៌មាន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងតំណាងក្រុមប្រឹក្សាអ្នកច្បាប់ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ អង្គភាពប្រឆាំងអំពើពុករលួយ គណៈកម្មការភាសាវិទ្យាខ្មែរ អគ្គនាយក ប្រធាននាយកដ្ឋាន និងមន្ត្រីជំនាញចំណុះទីស្តីការគណៈរដ្ឋមន្ត្រី ដូចមានក្នុងបញ្ជីវត្តមានភ្ជាប់មកជាមួយ។

ជាកិច្ចចាប់ផ្តើម ឯកឧត្តមប្រធានអង្គប្រជុំបានមានមតិស្វាគមន៍ចំពោះសមាជិក សមាជិកានៃអង្គប្រជុំ ដោយបានលើកឡើងជុំវិញសេចក្តីព្រាងនៃបទបញ្ជានេះ ដូចជា គោលបំណង មូលហេតុ សារបាន និងផលប្រយោជន៍ ហើយថែមទាំងបានរម្លឹកពីនីតិវិធីដាក់មកទីស្តីការគណៈរដ្ឋមន្ត្រីកន្លងមក និងបានអនុញ្ញាតជូនលោកជំទាវ **គីម សេដ្ឋានី** រដ្ឋលេខាធិការប្រចាំការក្រសួងអប់រំ យុវជន និងកីឡា ធ្វើសេចក្តីថ្លែងហេតុរៀបរាប់ពីគោលបំណង មូលហេតុ សារបាន និងផលប្រយោជន៍ជារួមនៃបទបញ្ជាខាងលើ ដោយបានមើលឃើញពីស្ថានភាពប៉ះពាល់ធ្ងន់ធ្ងរសុខភាពប្រជាជនកម្ពុជា ជាពិសេសបុគ្គលិកអប់រំ សិស្ស និស្សិតនៅកម្ពុជា ក៏ដូចជាសុខភាពសាធារណៈ និងការចំណាយថវិកា ជាតិគាំពារសង្គម នាពេលអនាគត ពាក់ព័ន្ធនឹងការប្រើប្រាស់ឧបករណ៍អេឡិចត្រូនិក និងសារធាតុគីមីចម្រុះរសជាតិ និងក្លិនដែលកំពុងហូរចូលព្រះរាជាណាចក្រកម្ពុជា មកអូសទាញយុវសិស្សនិងយុវជន ហើយបំផ្លាញសុខភាព ក៏ដូចជា សណ្តាប់ធ្នាប់សង្គមជាតិនាពេលបច្ចុប្បន្ន។



៥

ជាកិច្ចបន្ទាប់ ឯកឧត្តមតំណាងក្រុមប្រឹក្សាអ្នកច្បាប់ និងឯកឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ព្រមទាំងឯកឧត្តម លោកជំទាវ សមាជិក សមាជិកា តំណាងក្រសួងស្ថាប័ន បានលើកមតិយោបល់ជូនអង្គប្រជុំពាក់ព័ន្ធនឹងសេចក្តីព្រាងនៃបទបញ្ញាខាងលើ ដោយលើកឡើងពីការគាំទ្រទាំងស្រុងនូវបទបញ្ញានេះ។

បន្ទាប់ពីពិនិត្យនិងពិភាក្សាគ្នាយ៉ាងល្អិតល្អន់រួចមក អង្គប្រជុំបានឯកភាពកែសម្រួល ដូចខាងក្រោម៖

**កថាខណ្ឌទី១ ៖**

បន្ទាត់ទី២ ៖ បន្ថែមពាក្យ "ឱ្យ" ពីក្រោយពាក្យ "មូលធនមនុស្ស" និងបន្ថែមពាក្យ "ដែល" ពីក្រោយពាក្យ "សុខភាពល្អ"

បន្ទាត់ទី៥ ៖ លុបពាក្យ "ជាពិសេស" ចេញ

បន្ទាត់ទី៦ ៖ ប្តូរពាក្យ "យុវវ័យ" ទៅជាពាក្យ "យុវជន"

បន្ទាត់ទី៧ ៖ ប្តូរពាក្យ "និង" ទៅជាពាក្យ "ជាពិសេស"

បន្ទាត់ទី១០ ៖ ប្តូរពាក្យ "យុវវ័យ" ទៅជាពាក្យ "យុវជន"

**កថាខណ្ឌទី២ ៖**

គ្រប់ពាក្យ "ប៊ីត ហ៊ីត ស្រូប" ត្រូវលុបចេញទាំងអស់

បន្ទាត់ទី១ ៖ យកពាក្យ "បង្ការ" ដាក់ពីមុខពាក្យ "ទប់ស្កាត់" វិញ

បន្ទាត់ទី២ ៖ បន្ថែមពាក្យ "ជាពិសេស" ពីមុខឃ្លា "សុខភាពរបស់អ្នកសិក្សានិងបុគ្គលិកអប់រំ"

"ចំណុចទី២ចាស់" ប្តូរទៅជា "ចំណុចទី៦ថ្មី" វិញ និងបន្ថែមពាក្យ "នេះ" ពីក្រោយពាក្យ "ស៊ីស្សា"

ចំណុចទី៤ បន្ទាត់ទី១ ៖ យកពាក្យ "បង្ការ" ដាក់ពីមុខពាក្យ "ទប់ស្កាត់" វិញ

"ចំណុចទី៥ចាស់" ប្តូរទៅជា "ចំណុចទី២ថ្មី" វិញ និងលុបពាក្យ "និង" ខាងមុខពាក្យ "ក្រសួងព័ត៌មាន" ចេញ រួចបន្ថែមពាក្យ "និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍" បន្ទាប់ពីឃ្លា "ក្រសួងព័ត៌មាន"

"ចំណុចទី៦ចាស់" ប្តូរទៅជា "ចំណុចទី៥ថ្មី" វិញ

ចំណុចទី៨ បន្ទាត់ទី៥ ៖ បន្ថែមឃ្លា "ទោះជាប្រភេទអាជីវកម្ម សេវាកម្មអ្វីក៏ដោយ" នៅពីក្រោយឃ្លា "ក្រសួង ស្ថាប័ន ឬអាជ្ញាធរពាក់ព័ន្ធ" និងលុបប្រយោគ "ករណីមិនរាងចាល ត្រូវដកហូត និងលុបចោលវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម អាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម" ចេញ

អង្គប្រជុំបានបញ្ចប់សព្វគ្រប់នៅវេលាម៉ោង១២និង៣០នាទីថ្ងៃត្រង់ នាថ្ងៃខែឆ្នាំដដែល ប្រកបដោយស្មារតីឯកភាព និងទទួលខុសត្រូវខ្ពស់។

អ្នកធ្វើរបាយការណ៍

នុត ចាន់វីរៈ

បានពិនិត្យត្រឹមត្រូវ
ប្រធាននាយកដ្ឋាន

អ៊ុត សំអ៊ាត

បានពិនិត្យត្រឹមត្រូវ
អគ្គនាយក

ឡុង សុខា

បានឃើញនិងឯកភាព
ប្រធានអង្គប្រជុំ

ស៊ា ម៉ៅ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

លេខ: ១៥ ហក.សរ

ថ្ងៃ ចន្ទ ១២រោច ខែ មាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ២០២៥

# របាយការណ៍

## ស្តីពី

## លទ្ធផលនៃកិច្ចប្រជុំជំនាញបច្ចេកទេស ពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីវិធានការហាមឃាត់ការនាំចូល ការចែកចាយ ការលក់ ការផ្សាយពាណិជ្ជកម្ម ការប្រើប្រាស់ ការកាន់កាប់ ការផលិត និងការស្តុកទុកឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្សា

កាលពីថ្ងៃអង្គារ ៦រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនិងថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២៥ វេលាម៉ោង ៨:៣០នាទីព្រឹក នៅបន្ទប់ប្រជុំ ៧-០៨ ជាន់ទី៧ នៅអគារភាតរភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី មានកិច្ចប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាពសហប្រធានឯកឧត្តម **សុក ផេង** រដ្ឋលេខាធិការ អនុប្រធាននិងជាប្រធានក្រុមការងារទី៣នៃក្រុមប្រឹក្សាអ្នកច្បាប់ និងឯកឧត្តម **នៅ បោនន័រ** សមាជិកអចិន្ត្រៃយ៍ និងជាសមាជិកក្រុមការងារទី៣ នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។

កិច្ចប្រជុំមានការអញ្ជើញចូលរួមពីឯកឧត្តម **អ៊ុន វីរជាតិ** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ឯកឧត្តម **សេត មូហាំម៉ាត់ស៊ីស** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី លោកជំទាវ **គឹម សេដ្ឋានី** រដ្ឋលេខាធិការប្រចាំការក្រសួងអប់រំ យុវជន និងកីឡា ឯកឧត្តម **យឹត ស៊ុនណារ៉ា** រដ្ឋលេខាធិការក្រសួងសុខាភិបាល តំណាងក្រុមប្រឹក្សាអ្នកច្បាប់ តំណាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ អគ្គនាយក ប្រធាននាយកដ្ឋាន និងមន្ត្រីជំនាញនៃទីស្តីការគណៈរដ្ឋមន្ត្រី ដូចមានក្នុងបញ្ជីវត្តមានគោរពជូនភ្ជាប់។

ជាកិច្ចចាប់ផ្តើម ឯកឧត្តមសហប្រធានបានថ្លែងអំណរគុណដល់សមាជិកអង្គប្រជុំ និងបានជម្រាបជូនអង្គប្រជុំថា សេចក្តីព្រាងអនុក្រឹត្យស្តីពីវិធានការហាមឃាត់ការនាំចូល ការចែកចាយ ការលក់ ការផ្សាយពាណិជ្ជកម្ម ការប្រើប្រាស់ ការកាន់កាប់ ការផលិត និងការស្តុកទុកឧបករណ៍អេឡិចត្រូនិក និងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្សា គឺជាកិច្ចការ បន្ទាន់។ បន្ទាប់មក ឯកឧត្តមសហប្រធានបានអញ្ជើញតំណាងក្រសួងអប់រំ យុវជន និងកីឡា ធ្វើសេចក្តីថ្លែងហេតុ ជូនអង្គប្រជុំ។

បន្ទាប់ពីបានពិភាក្សាគ្នាយ៉ាងផុសផុល អង្គប្រជុំបានឯកភាពគ្នាឱ្យក្រសួងសាមី គោរពស្នើសុំគោលការណ៍អនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **សម្តេចធិបតីនាយករដ្ឋមន្ត្រី** ជាមុនសិននូវជម្រើសណាមួយ ដូចខាងក្រោម៖

១- ចេញជាបទបញ្ញារបស់រាជរដ្ឋាភិបាល ឬអនុក្រឹត្យមានលក្ខណៈជាបទបញ្ញាទូទៅ។

២- ធ្វើវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់ ឬបង្កើតច្បាប់ថ្មី។

ក្នុងន័យនេះ គោលជំហរក្រុមប្រឹក្សាអ្នកច្បាប់ ស្នើសុំចេញបទបញ្ញារបស់រាជរដ្ឋាភិបាល ព្រោះថាបើចេញជាអនុក្រឹត្យ នាំឱ្យមានអំពើអនីត្យានុកូលភាពនៃច្បាប់ ហើយក្នុងខ្លឹមសារក៏ប៉ះពាល់ទៅនឹងទិដ្ឋភាពច្បាប់។ អនុក្រឹត្យមិនអាចបញ្ញត្តិដកហូតកម្មសិទ្ធិបុគ្គលបានឡើយ។ ការដកហូតសិទ្ធិនិងសេរីភាពបុគ្គល ជាសមត្ថកិច្ចរបស់អង្គនីតិបញ្ញត្តិ។ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ គាំទ្រដល់ស្មារតីអង្គប្រជុំចំពោះជម្រើសទាំង២ និងរង់ចាំការណែនាំដ៏ខ្ពង់ខ្ពស់ពី **សម្តេចអធិបតីនាយករដ្ឋមន្ត្រី** លើជម្រើសសមស្របដើម្បីជានាការអនុវត្តប្រកបដោយប្រសិទ្ធភាព និងទាន់សភាពការណ៍។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង១១និង២០នាទីព្រឹក នាថ្ងៃខែឆ្នាំដដែល។

**អ្នកធ្វើរបាយការណ៍**

**នុត ចាន់វីរៈ**

**បានពិនិត្យត្រឹមត្រូវ**
**ប្រធាននាយកដ្ឋានស្តីទី**

**អ៊ុត សំអ៊ាត**

**បានពិនិត្យត្រឹមត្រូវ**
**អគ្គនាយករង**

**ខុន សុធន**

**បានឃើញនិងឯកភាព**

**សុក ផេង**

**នៅ បោនន័រ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
ក្រុមការងារទី៣

# របាយការណ៍
# ស្តីពី
# សេចក្តីព្រាងអនុក្រឹត្យស្តីពី
# វិធានការហាមឃាត់ការនាំចូល ការចែកចាយ ការលក់ ការផ្សាយពាណិជ្ជកម្ម ការប្រើប្រាស់ ការកាន់កាប់ ការផលិត និងការស្តុកទុកឧបករណ៍អេឡិចត្រូនិក និងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្សា

## ១. ប្រភពនៃសេចក្តីព្រាង

១.១- ក្រសួង ស្ថាប័ន សាមី

- ស្ថាប័ន: ក្រសួងអប់រំ យុវជន និងកីឡា
- តំណាង: ឯកឧត្តមបណ្ឌិតសាភាចារ្យ ហង់ជួន ណារ៉ុន

១.២- កាលបរិច្ឆេទដាក់ស្នើមកទីស្តីការគណៈរដ្ឋមន្ត្រី

- បញ្ជូនមកទីស្តីការគណៈរដ្ឋមន្ត្រី នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៥
- បញ្ជូនមក ក.ស.វ. នៅថ្ងៃទី ២២ ខែមករា ឆ្នាំ២០២៥

## ២. មូលដ្ឋានបន្ថែមនៃសេចក្តីព្រាង

-រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៧២ បានកំណត់ថា សុខភាពរបស់ប្រជាពលរដ្ឋត្រូវបានធានា

-ច្បាប់ស្តីពីការអប់រំ មាត្រា៤១ កំណត់អំពីសិទ្ធិរបស់អ្នកសិក្សានិងបុគ្គលិកអប់រំក្នុងការត្រួតពិនិត្យសុខភាពដែលមានខ្លឹមសារថា "អ្នកសិក្សានិងបុគ្គលិកអប់រំនៃគ្រឹះស្ថានសិក្សាដែលមានអាជ្ញាបណ្ណ អប់រំមានសិទ្ធិទទួលបាននូវការពិនិត្យសុខភាព"

-គោលនយោបាយជាតិស្តីពីសុខភាពសិក្សាដែលបានជំរុញឱ្យគ្រប់ក្រសួង ស្ថាប័នដែលមានគ្រឹះស្ថានសិក្សាឱ្យយកចិត្តទុកដាក់ចំពោះសុខភាពរបស់អ្នកសិក្សានិងបុគ្គលិកអប់រំ សំដៅអភិវឌ្ឍធនធានមនុស្សឱ្យមានលក្ខណសម្បត្តិពេញលេញនិងមានសុខភាពល្អទាំងកាយសម្បទា បញ្ញា ស្មារតី ដើម្បីអភិវឌ្ឍសង្គមកម្ពុជាប្រកបដោយចីរភាព ឈានទៅសម្រេចគោលដៅអភិវឌ្ឍជាតិក្លាយជាប្រទេសមាន ចំណូលមធ្យមកម្រិតខ្ពស់នាឆ្នាំ២០៣០ និងជាប្រទេសអភិវឌ្ឍន៍ពេញលេញនាឆ្នាំ២០៥០

-អនុសាសន៍របស់អង្គការសុខភាពពិភពលោក ឱ្យរដ្ឋជាសមាជិកយកចិត្តទុកដាក់ទប់ស្កាត់ការប្រើប្រាស់ឧបករណ៍អេឡិចត្រូនិកសម្រាប់ជក់ ហើយវិធានការមានប្រសិទ្ធភាពបំផុត គឺការហាមឃាត់ការប្រើប្រាស់រួមទាំងការផលិតនិងការនាំចូលឧបករណ៍នេះ។

## ៣. បញ្ហាប្រឈមដែលនាំឱ្យមានការបង្កើតសេចក្តីព្រាង

-ការប្រើប្រាស់ និងការបង្ហោះផ្សព្វផ្សាយលក់តាមបណ្តាញព័ត៌មាននូវឧបករណ៍អេឡិចត្រូនិកមិនបានថយចុះនៅឡើយបើទោះបីជាមានការណែនាំនាពេលកន្លងមក

-ការប្រើប្រាស់ឧបករណ៍អេឡិចត្រូនិកសម្រាប់ជក់ កំពុងរីករាលដាលគួរអោយព្រួយបារម្ភ ក្នុង ចំណោមកុមារនិងយុវជន មិនថានៅរាជធានី ឬនៅបណ្តាខេត្ត

-ការប្រើប្រាស់ឧបករណ៍អេឡិចត្រូនិកសម្រាប់ជក់ បណ្តាលអោយមានការប៉ះពាល់យ៉ាងខ្លាំង ដល់មូលធនមនុស្សជំនាន់ក្រោយរបស់កម្ពុជា ព្រោះចំហាយចេញពីឧបករណ៍អេឡិចត្រូនិក សម្រាប់ជក់ផ្ទុកសារធាតុញៀន និងសារធាតុបង្កគ្រោះថ្នាក់ ដែលបង្អាក់ដល់ការលូតលាស់ខួរ ក្បាល និងបំផ្លាញសុខភាពជាទម្ងន់ដល់កុមារនិងយុវជន

-ការរៀបចំសេចក្តីព្រាងអនុក្រឹត្យនេះ តម្រូវទៅតាមបរិបទសាកលភាវូបនីយកម្មនិងការរីកចម្រើនផ្នែកបច្ចេកវិទ្យាដែល មានលេចចេញនូវឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់និងស៊ីស្សាដែលមានហានិភ័យខ្ពស់ សម្រាប់សុខភាព និងពុំទាន់មានវិធានសម្រាប់គ្រប់គ្រងនិងប្រើប្រាស់ឱ្យបានច្បាស់លាស់នៅឡើយទេ។

## ៤. គោលបំណងនៃការបង្កើតសេចក្តីព្រាង

-អនុក្រឹត្យនេះ មានគោលបំណងការពារសុខភាពសាធារណៈ សុខភាពអ្នកសិក្សា បុគ្គលិកអប់រំ និងកម្មករនិយោជិត ដោយកំណត់អំពីវិធានការ យន្តការ បែបបទ និងនីតិវិធីក្នុងការគ្រប់គ្រង ជាពិសេសហាមឃាត់ការនាំចូល ការចែកចាយ ការលក់ ការផ្សាយពាណិជ្ជកម្ម ការប្រើប្រាស់ ការកាន់កាប់ការផលិត និងការស្តុកទុក ឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ បឺត ហឺត ស្រូប និងស៊ីស្សា។

## ៥. ការពិភាគជម្រើសផ្សេងៗ

-ក្រសួងសាមីពុំមានជម្រើសផ្សេងទៀត

## ៦. ការវាយតម្លៃលើផលប៉ះពាល់/ការពិភាគបន្ទុកចំណាយ និងផលចំណេញ

### ៦.១. ផលប៉ះពាល់អវិជ្ជមាន/បន្ទុកចំណាយ

-ការកើនឡើងនៃទីផ្សារខុសច្បាប់៖ ការហាមឃាត់អាចនាំឱ្យមានការកើនឡើងនៃទីផ្សារខុសច្បាប់ ដែលអាចធ្វើឱ្យកាន់តែពិបាកក្នុងការគ្រប់គ្រង និងត្រួតពិនិត្យផលិតផលទាំងនេះ

-ការប្រឈមនឹងការតវ៉ា៖ អ្នកដែលពឹងផ្អែកលើផលិតផលទាំងនេះអាចនឹងតវ៉ា ឬប្រឆាំងនឹងវិធានការនេះ ដែលអាចនាំឱ្យមានភាពមិនស្ថិតស្ថេរក្នុងសង្គម។

-ប៉ះពាល់ដល់ទេសចរ

-បាត់ប្រយោជន៍អ្នកលក់និងអ្នកប្រើប្រាស់ស៊ីស្សា

-រដ្ឋាភិបាលត្រូវចំណាយលើអនុវត្តវិធានការទប់ស្កាត់

-ចំណាយច្រើនជាងមុនទៅលើការអប់រំ ផ្សព្វផ្សាយសាធារណៈ

### ៦.២. ផលចំណេញ/ផលប៉ះពាល់វិជ្ជមាន

-លើកកម្ពស់សុខភាពសាធារណៈ កាត់បន្ថយជំងឺមិនឆ្លង កាត់បន្ថយការចំណាយលើសុខភាពសាធារណៈរបស់រដ្ឋ(ប.ស.ស.)

-ការពារកុមារនិងយុវជនពីផលប៉ះពាល់ទៅលើសុខភាព និងការសិក្សា

-ក្នុងរយៈពេលវែងអាចកសាងធនធានមនុស្សបាន

-ការកាត់បន្ថយបញ្ហាសុខភាព៖ ការហាមឃាត់នេះអាចជួយកាត់បន្ថយការប្រើប្រាស់ផលិតផល ដែលបង្កគ្រោះថ្នាក់ដល់សុខភាព ដូចជាការជក់ និងការប្រើប្រាស់ស៊ីស្សា ដែលអាចនាំឱ្យមានការថយចុះនូវជំងឺផ្លូវដង្ហើម ជំងឺបេះដូង និងមហារីក។

-ការកាត់បន្ថយការប្រព្រឹត្តិខុសច្បាប់៖ ការហាមឃាត់នេះអាចជួយកាត់បន្ថយការលក់ និងការប្រើប្រាស់ផលិតផលខុសច្បាប់ ដែលអាចនាំឱ្យមានសុវត្ថិភាពសង្គមកាន់តែប្រសើរឡើង។

-ការលើកកម្ពស់ការយល់ដឹងសង្គម៖ ការហាមឃាត់នេះអាចជួយលើកកម្ពស់ការយល់ដឹងរបស់សាធារណជនអំពីគ្រោះថ្នាក់របស់ផលិតផលទាំងនេះ និងលើកកម្ពស់វប្បធម៌នៃការរស់នៅដោយមានសុខភាពល្អ។

-កាត់បន្ថយការបំពុលបរិស្ថាន៖ ការហាមឃាត់នេះអាចជួយកាត់បន្ថយការបំពុលបរិស្ថានដែលកើតចេញពីការប្រើប្រាស់ និងការបោះចោលផលិតផលទាំងនេះ។

## ៧. ការពិគ្រោះយោបល់ក្នុងដំណើរការរៀបចំ

-ក្រសួងអប់រំ យុវជន និងកីឡា បានសហការជាមួយក្រសួងសុខាភិបាល ក្រសួង ស្ថាប័ន និងដៃគូ ពាក់ព័ន្ធ ដោយបង្កើតក្រុមការងាររៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីវិធានការហាមឃាត់ការនាំចូល ការចែកចាយ ការលក់ ការផ្សាយពាណិជ្ជកម្ម ការប្រើប្រាស់ ការកាន់កាប់ ការផលិត និងការស្តុកទុកឧបករណ៍អេឡិចត្រូនិក និងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្សា

-កិច្ចប្រជុំគណៈកម្មាធិការអន្តរក្រសួងស្តីពីសុខភាពសិក្សាដើម្បីស្វែងរកវិធានការដើម្បីបង្ការនិងទប់ស្កាត់ការប្រើប្រាស់និងចែកចាយបារីអេឡិចត្រូនិកចំណោមយុវជន នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៤

-សេចក្តីព្រាងអនុក្រឹត្យនេះ បានឆ្លងកាត់ប្រជុំបច្ចេកទេសជាច្រើនលើក និងកិច្ចប្រជុំអន្តរក្រសួងស្តីពីសុខភាពសិក្សា នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២៤ ដែលដឹកនាំកិច្ចប្រជុំដោយឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងមានការចូលរួមពីតំណាងគណៈរដ្ឋមន្ត្រី ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ ថ្នាក់ដឹកនាំក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត និងអ្នកជំនាញ សរុបចំនួន ៩៤រូប។

-ឯកសារនេះបានដាក់ឆ្លងកិច្ចប្រជុំផ្តល់យោបល់ពីគណៈកម្មាធិការអន្តរក្រសួងស្តីពីសុខភាពសិក្សា ដោយមានការចូលរួមពីតំណាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី និងអ្នកជំនាញជាច្រើនរូប។

## ៨. យន្តការអនុវត្ត តាមដានត្រួតពិនិត្យ និងវាយតម្លៃ

-ការអនុវត្តយន្តការត្រួតពិនិត្យមានភាពតឹងរ៉ឹង

## ៩. សេចក្តីសន្និដ្ឋាន/យោបល់រួមរបស់ក.ស.វ.

-អនុក្រឹត្យនេះមានគោលបំណងកាត់បន្ថយបញ្ហាសុខភាព និងបរិស្ថាន ប៉ុន្តែក៏មានផលប៉ះពាល់អវិជ្ជមានដល់សេដ្ឋកិច្ច និងសង្គមផងដែរ

-ដើម្បីធានាបាននូវប្រសិទ្ធភាពរបស់វិធានការនេះរដ្ឋាភិបាលត្រូវពិចារណាទៅលើការគ្រប់គ្រងទីផ្សារខុសច្បាប់ ការផ្តល់ជំនួយដល់អ្នកដែលពឹងផ្អែកលើផលិតផលទាំងនេះ និងការលើកកម្ពស់ការយល់ដឹងសាធារណៈអំពីគ្រោះថ្នាក់របស់ផលិតផលទាំងនេះ។ ការរួមបញ្ចូលគ្នារវាងវិធានការច្បាប់ និងការអប់រំអាចជួយឱ្យវិធានការនេះទទួលបានជោគជ័យ។

-ការបង្កើតវិធានការហាមឃាត់អាចមានផលប៉ះពាល់ទាំងវិជ្ជមាន និងអវិជ្ជមានដល់សង្គម។ ដូច្នេះការអនុវត្តវិធានការទាំងនេះត្រូវតែធ្វើឡើងដោយមានការគិតគូរយ៉ាងហ្មត់ចត់ និងមានការគាំទ្រពីសង្គម។

ជាយោបល់ ក.ស.វ. ៖

១- គួរចេញជាបទបញ្ញារបស់រាជរដ្ឋាភិបាល ឬអនុក្រឹត្យមានលក្ខណៈជាបទបញ្ញាទូទៅ។
២- ធ្វើវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់ ឬបង្កើតច្បាប់ថ្មី។
៣- ស្នើក្រសួងសាមីរៀបចំរបាយការណ៍វាយតម្លៃលិខិតបទដ្ឋានគតិយុត្ត RIAឱ្យបានគ្រប់ជ្រុងជ្រោយ
៤- ស្នើក្រសួងសាមីរៀបចំសេចក្តីព្រាងផែនការនេះ ឱ្យស្របទៅនឹងទម្រង់ទីស្តីការគណៈរដ្ឋមន្ត្រី
៥- ស្នើក្រសួងសាមីធ្វើបច្ចុប្បន្នភាព ទិន្នន័យឱ្យច្បាស់លាស់។
៦- ឧបករណ៍ទាំងអស់នេះ ពេលគ្រប់គ្រង យន្តការអនុវត្តជាក់ស្តែង ត្រូវមានយុទ្ធសាស្ត្រអនុវត្ត យ៉ាងដូចម្តេច?
៧- តើតួនាទីអប់រំផ្សព្វផ្សាយរបស់ក្រសួងអប់រំ តើគួរបង្រឹងយ៉ាងដូចម្តេច?
៨- មិនទាន់កំណត់ឱ្យច្បាស់អំពីបែបបទ
៩- មិនទាន់កំណត់ឱ្យច្បាស់អំពីវិធានការ
១០- មិនទាន់កំណត់ឱ្យច្បាស់អំពីយន្តការ
១១- មិនទាន់កំណត់ឱ្យច្បាស់អំពីនីតិវិធីក្នុងការគ្រប់គ្រង
១២- និយមការផ្សាយពាណិជកម្ម មានកំណត់ក្នុងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់។
១៣- មាត្រាទី១៦ តើមានច្បាប់ណាមួយបានចែងពីការដកសិទ្ធពីអ្នកប្រើប្រាស់?
១៤- ចំពោះកុមារនិងយុវជន ហាមដាច់ខាត ក្នុងការប្រើប្រាស់ស៊ីស្សា
១៥- ចំពោះអ្នកវ័យកណ្តាល និងអ្នកទេសចរ គួរអនុវត្តជាដំណាក់កាល
១៦- ត្រូវលើកម្ពស់អប់រំ ផ្សព្វផ្សាយ អំពីផលប៉ះពាល់នៃការប្រើប្រាស់ស៊ីស្សា(ប្រសិនបើមានរោងចក្រផលិតស៊ីស្សា វិញ) តើរដ្ឋាភិបាល គួរចាត់វិធានសម្រាប់ការអនុវត្តនិងផលិតផលផ្សេងវិញ ឬកុំចរាចរកលក់ក្នុងស្រុក?
១៧- តាមដាននិងត្រួតពិនិត្យឱ្យមានប្រសិទ្ធខ្ពស់

ថ្ងៃចន្ទ ១៣ កើត ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៥
អ្នកធ្វើរបាយការណ៍

បានពិនិត្យនិងឯកភាព
ប្រធានក្រុមការងារទី៣

ចែម ផល្លា

ញឹម បូង៉ាន

នៅ បោនន័រ

**បានឃើញនិងឯកភាព**
**ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធាន ក.ស.វ.**

**ឆែម គាតរិទ្ធី**

31.01.25 14:30 ... 204

30.01.25

...ជា

...ក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
ចូល លេខ 184 ថ្ងៃ 16 ខែ 01 ឆ្នាំ 2025 ម៉ោង 16:00

អគ្គនាយកដ្ឋានកិច្ចការប្រជុំនិងសហប្រ...
ថ្ងៃ 21 ខែ 01 ឆ្នាំ 2025 ម៉ោង ... លេខ 321

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី**
**នៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ៖** គោរពស្នើសុំប្រជុំឆ្លងសេចក្តីព្រាងអនុក្រឹត្យស្តីពីវិធានការហាមឃាត់ការនាំចូល ការចែកចាយ ការលក់ ការផ្សាយពាណិជ្ជកម្ម ការប្រើប្រាស់ ការកាន់កាប់ ការផលិត និងការស្តុកទុកឧបករណ៍អេឡិចត្រូនិក និងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្សា។

**យោង៖** តាមការចាំបាច់របស់ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសុខាភិបាល។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ យើងខ្ញុំមានកិត្តិយសសូមគោរពជម្រាបជូន សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា៖ ដោយមើលឃើញពីផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សុខភាពប្រជាជនកម្ពុជាពិសេសសិស្សានុសិស្ស ពីការប្រើប្រាស់ឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្សាដែលកំពុងតែកើតមាននៅព្រះរាជាណាចក្រកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយក្រសួងសុខាភិបាល បានរៀបចំសេចក្តីព្រាងអនុក្រឹត្យ ស្តីពីវិធានការហាមឃាត់ការនាំចូល ការចែកចាយ ការលក់ ការផ្សាយពាណិជ្ជកម្ម ការប្រើប្រាស់ ការកាន់កាប់ ការផលិត និងការស្តុកទុកឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្សានេះឡើង និងបានដាក់ឆ្លងកិច្ចប្រជុំផ្តល់យោបល់ពីគណៈកម្មាធិការអន្តរក្រសួងស្តីពីសុខភាពសិក្សា ដោយមានការចូលរួមពីតំណាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី និងអ្នកជំនាញជាច្រើនរូប។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី មេត្តាពិនិត្យនិងសម្រេចដោយសេចក្តីអនុគ្រោះ។

សូម សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់បំផុតពីយើងខ្ញុំ ។

ថ្ងៃ ចន្ទ ១៣ កើត ខែ បុស្ស ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**រដ្ឋមន្ត្រី**
**ក្រសួងសុខាភិបាល**

សាស្ត្រាចារ្យ **ឈាង រ៉ា**

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខៈ** ៣៤ **អយក.**នក

ទីស្តីការគណៈរដ្ឋមន្ត្រី
ចូល លេខ 184 ថ្ងៃទី 16 ខែ 01 ឆ្នាំ 2025 ម៉ោង 16h00

ទីស្តីការគណៈរដ្ឋមន្ត្រី
អគ្គនាយកដ្ឋានកិច្ចការប្រជុំនិងសរុប
ចូល ថ្ងៃទី 21 ខែ 01 ឆ្នាំ 2025 ម៉ោង 4h00 លេខ 331 អ.ប.ស

**សូមគោរពជូន**
**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី**
**នៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ៖** គោរពស្នើសុំប្រជុំឆ្លងសេចក្តីព្រាងអនុក្រឹត្យស្តីពីវិធានការហាមឃាត់ការនាំចូល ការចែកចាយ ការលក់ ការផ្សាយពាណិជ្ជកម្ម ការប្រើប្រាស់ ការកាន់កាប់ ការផលិត និងការស្តុកទុកឧបករណ៍អេឡិចត្រូនិក និងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្សា។

**យោង៖** តាមការចាំបាច់របស់ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសុខាភិបាល។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ យើងខ្ញុំមានកិត្តិយសសូមគោរពជម្រាបជូន **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា៖ ដោយមើលឃើញពីផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សុខភាពប្រជាជនកម្ពុជាពិសេសសិស្សានុសិស្ស ពីការប្រើប្រាស់ឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្សាដែលកំពុងតែកើតមាននៅព្រះរាជាណាចក្រកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយក្រសួងសុខាភិបាល បានរៀបចំសេចក្តីព្រាងអនុក្រឹត្យ ស្តីពីវិធានការហាមឃាត់ការនាំចូល ការចែកចាយ ការលក់ ការផ្សាយពាណិជ្ជកម្ម ការប្រើប្រាស់ ការកាន់កាប់ ការផលិត និងការស្តុកទុកឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្សានេះឡើង និងបានដាក់ឆ្លងកិច្ចប្រជុំផ្តល់យោបល់ពីគណៈកម្មាធិការអន្តរក្រសួងស្តីពីសុខភាពសិក្សា ដោយមានការចូលរួមពីតំណាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី និងអ្នកជំនាញជាច្រើនរូប។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យនិងសម្រេចដោយសេចក្តីអនុគ្រោះ។

សូម **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់បំផុតពីយើងខ្ញុំ ។

ថ្ងៃ ចន្ទ ៨ កើត ខែ បុស្ស ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ២០២៥

| | |
|---|---|
| **ឧបនាយករដ្ឋមន្ត្រី** | **រដ្ឋមន្ត្រី** |
| **រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា** | **ក្រសួងសុខាភិបាល** |
| បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** | សាស្ត្រាចារ្យ **ឈាង រ៉ា** |

# អនុក្រឹត្យ
# ស្តីពី
# វិធានការហាមឃាត់ការនាំចូល ការចែកចាយ ការលក់ ការផ្សាយពាណិជ្ជកម្ម ការប្រើប្រាស់ ការកាន់កាប់ ការផលិត និងការស្តុកទុកឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ និងស៊ីសា្ស

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ១០១ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងតាមការចាំបាច់និងភាពបន្ទាន់ក្នុងការការពារសុខភាពសាធារណៈសុខភាពអ្នកសិក្សានិងបុគ្គលិកអប់រំ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ ..**

អនុក្រឹត្យនេះ មានគោលបំណងការពារសុខភាពសាធារណៈ សុខភាពអ្នកសិក្សា បុគ្គលិកអប់រំ និងកម្មករនិយោជិត ដោយកំណត់អំពីវិធានការ យន្តការ បែបបទ និងនីតិវិធីក្នុងការគ្រប់គ្រង ជាពិសេសហាមឃាត់ ការនាំចូល ការចែកចាយ ការលក់ ការផ្សាយពាណិជ្ជកម្ម ការប្រើប្រាស់ ការកាន់កាប់ការផលិត និងការស្តុកទុកឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ បឺត ហឺត ស្រូប និងស៊ីស្សា។

**មាត្រា២ ..**

អនុក្រឹត្យនេះមានវិសាលភាពគ្របដណ្តប់ទៅលើការនាំចូល ការចែកចាយ ការលក់ ការផ្សាយពាណិជ្ជកម្ម ការប្រើប្រាស់ ការកាន់កាប់ ការផលិត និងការស្តុកទុកឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ បឺត ហឺត ស្រូប និងស៊ីស្សាគ្រប់ប្រភេទ គ្រប់ទម្រង់ និងគ្រប់មធ្យោបាយ រួមទាំងមធ្យោបាយឌីជីថលដែលកើតមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣ ..**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះត្រូវបានកំណត់ ដូចខាងក្រោម៖

១). **ការផ្សាយពាណិជ្ជកម្ម** សំដៅដល់រាល់ទម្រង់នៃទំនាក់ទំនងពាណិជ្ជកម្ម ការផ្តល់អនុសាសន៍ ឬសកម្មភាព ការចូលរួមក្នុងរាល់ព្រឹត្តិការណ៍ សកម្មភាព ឬបុគ្គល ក្នុងគោលបំណង ជំរុញអូសទាញ និងលើកទឹកចិត្តការប្រើប្រាស់ឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ បឺត ហឺត ស្រូប និងស៊ីស្សា។

២). **ឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ បឺត ហឺត ស្រូប និងស៊ីស្សា** សំដៅដល់រាល់ផលិតផល ឬផ្នែកនៃផលិតផលដែលត្រូវបានរចនាបង្កើតឡើងសម្រាប់បញ្ជូនសារធាតុថ្នាំជក់ នីកូទីន ឬសារធាតុគីមីផ្សេងទៀតទៅអ្នកប្រើប្រាស់ តាមរយៈឧស្ម័ន ឬចំហាយដែលកើតឡើងដោយការដុតកម្តៅឬមធ្យោបាយប្រហាក់ប្រហែល។ ឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ បឺត ហឺត ស្រូប រួមមានជាអាទិ៍៖

- **បារីអេឡិចត្រូនិក** (Electronic cigarette / E-cigarette) ឬ**វេប** (Vape) គឺជាឧបករណ៍ដំណើរការដោយថ្មពិលឬថាមពលផ្សេងទៀត ដែលកម្តៅវត្ថុរាវឱ្យក្លាយជាចំហាយ ដែលស្រូបចូលដោយអ្នកជក់។
- **ផលិតផលអេចឈ៍ ធី ភី** (HTP: Heated Tobacco Product) គឺជាឧបករណ៍អគ្គិសនី ដែលកម្តៅស្លឹកថ្នាំជក់បង្កើតជាចំហាយសម្រាប់អ្នកជក់ បឺត ហឺត ស្រូបចូល។ ចំហាយនេះ ផ្ទុកនូវសារធាតុផ្តល់រសជាតិនិងក្លិន ។

៣). **ស៊ីស្សា** (Shisha) សំដៅដល់ទម្រង់មួយនៃថ្នាំជក់ ឬមិនមែនថ្នាំជក់ដែលមានរសជាតិផ្អែម និងក្លិន ដែលប្រើប្រាស់បំពង់តែមួយឬច្រើនសម្រាប់ឱ្យផ្សែងឆ្លងកាត់តាមទឹក ឬវត្ថុរាវផ្សេងទៀត មុននឹងទៅដល់អ្នកជក់។

## ជំពូកទី២
## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា៤ ..**

ក្រសួងសុខាភិបាល ត្រូវចេញសេចក្តីណែនាំ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងអប់រំផ្សព្វផ្សាយអំពីផលប៉ះពាល់សុខភាព និងគ្រោះថ្នាក់នៃការប្រើប្រាស់ឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ បឺត ហឺត ស្រូប និងស៊ីស្សា។

ក្រសួងសុខាភិបាល ត្រូវធ្វើការត្រួតពិនិត្យ និងចាត់វិធានការលើករណីប្រព្រឹត្តល្មើសនឹងអនុក្រឹត្យនេះ ដោយសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរដែលមានសមត្ថកិច្ចពាក់ព័ន្ធ។

**មាត្រា៥ ..**

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវចេញសេចក្តីណែនាំនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីអប់រំ បង្ការ ទប់ស្កាត់ការប្រើប្រាស់ឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ បឺត ហឺត ស្រូប និងស៊ីស្សា នៅក្នុងនិងជុំវិញបរិវេណគ្រឹះស្ថានសិក្សាសាធារណៈនិងឯកជន គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ អន្តេវាសិកដ្ឋាន មជ្ឈមណ្ឌលសិក្សាសហគមន៍ និងក្លឹបកីឡា។

**មាត្រា៦ ..**

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវចេញសេចក្តីណែនាំនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីអប់រំ បង្ការ ទប់ស្កាត់ការប្រើប្រាស់ឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ បឺត ហឺត ស្រូប និងស៊ីស្សា នៅក្នុងនិងជុំវិញបរិវេណសហគ្រាស គ្រឹះស្ថាន គ្រឹះស្ថានបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ និងអន្តេវាសិកដ្ឋាន។

**មាត្រា៧ ..**

ក្រសួងពាណិជ្ជកម្ម ត្រូវចេញសេចក្តីណែនាំនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីហាមឃាត់ការនាំចូល ការចែកចាយ ការផ្សាយពាណិជ្ជកម្ម ការលក់ និងការស្តុកទុកឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ បឺត ហឺត ស្រូប និងស៊ីស្សាដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ក្រសួងពាណិជ្ជកម្ម ត្រូវធ្វើការត្រួតពិនិត្យនិងចាត់វិធានការលើករណីប្រព្រឹត្តល្មើសនឹងអនុក្រឹត្យនេះ ដោយសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរដែលមានសមត្ថកិច្ចពាក់ព័ន្ធ។

**មាត្រា៨ ..**

ក្រសួងទេសចរណ៍ ត្រូវចេញសេចក្តីណែនាំនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីហាមឃាត់ការចែកចាយ ការផ្សាយពាណិជ្ជកម្ម ការលក់ ការប្រើប្រាស់ និងការស្តុកទុកឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ បឺត ហឺត ស្រូប និងស៊ីស្សានៅតាមមូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍ ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៩ ..**

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវចេញសេចក្តីណែនាំនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីហាមឃាត់ការផលិតនិងការស្តុកទុកឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ បឺត ហឺត ស្រូប និងស៊ីស្សា។

**មាត្រា១០ ..**

ក្រសួងមហាផ្ទៃ ត្រូវមានវិធានការទប់ស្កាត់និងបង្ក្រាប ការនាំចូល ការចែកចាយ ការផ្សាយពាណិជ្ជកម្ម ការលក់ និងការស្តុកទុកឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ បឺត ហឺត ស្រូប និងស៊ីស្យា។

**មាត្រា១១ ..**

ក្រសួងព័ត៌មាន ត្រូវចេញសេចក្តីណែនាំហាមឃាត់ការផ្សព្វផ្សាយពាក់ព័ន្ធនឹងឧបករណ៍អេឡិចត្រូនិក និងសារធាតុគីមីសម្រាប់ជក់ បឺត ហឺត ស្រូប និងស៊ីស្យា តាមបណ្តាញសារព័ត៌មាននិងត្រួតពិនិត្យ តាមដាន ដើម្បីចាត់វិធានការតាមផ្លូវច្បាប់។

**មាត្រា១២ ..**

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ត្រូវចេញសេចក្តីណែនាំហាមឃាត់ការផ្សព្វផ្សាយពាក់ព័ន្ធនឹង ឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ បឺត ហឺត ស្រូប និងស៊ីស្យា តាមបណ្តាញទំនាក់ទំនង សង្គម និងត្រួតពិនិត្យតាមដាន ដើម្បីចាត់វិធានការតាមផ្លូវច្បាប់។

**មាត្រា១៣ ..**

ក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវចេញសេចក្តីណែនាំនិងលិខិតបទដ្ឋានគតិយុត្ត ស្តីពីការហាម ឃាត់ការដឹកជញ្ជូន ឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ បឺត ហឺត ស្រូប និងស៊ីស្យា ដល់គ្រប់ អង្គភាពសាធារណៈនិងឯកជន ដែលពាក់ព័ន្ធនឹងវិស័យដឹកជញ្ជូន។

**មាត្រា១៤ ..**

ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវចេញសេចក្តីណែនាំនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការហាមឃាត់ ឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ បឺត ហឺត ស្រូប និងស៊ីស្យា ស្របតាមសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា១៥ ..**

រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវចាត់វិធានការផ្សព្វផ្សាយ អប់រំ បង្ការ ទប់ស្កាត់ និងបង្ក្រាបពាក់ព័ន្ធនឹងការ នាំចូល ការចែកចាយ ការលក់ ការផ្សាយពាណិជ្ជកម្ម ការប្រើប្រាស់ ការកាន់កាប់ ការផលិត និងការស្តុកទុក ឧបករណ៍អេឡិចត្រូនិក និងសារធាតុគីមីសម្រាប់ជក់ បឺត ហឺត ស្រូប និងស៊ីស្យា នៅតាមមូលដ្ឋានស្ថិតក្រោម ដែនសមត្ថកិច្ចរបស់ខ្លួន។

## ជំពូកទី៣
## ការហាមឃាត់

**មាត្រា១៦ ..**

ហាមឃាត់រាល់ការប្រើប្រាស់ កាន់កាប់ឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ បឺត ហឺត ស្រូប និងស៊ីស្យាគ្រប់ប្រភេទ។

**មាត្រា១៧ ..**

ហាមឃាត់ការចែកចាយ ការលក់ ការស្តុកទុកឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ បឺត ហឺត ស្រូប និងស៊ីស្យា តាមមធ្យោបាយណាក៏ដោយ។

**មាត្រា១៨ ..**

ហាមឃាត់ការផ្សព្វផ្សាយពាណិជ្ជកម្ម ការផ្សព្វផ្សាយលក់ឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ បឺត ហឺត ស្រូប និងស៊ីស្សាគ្រប់ប្រភេទ និងការឧបត្ថម្ភព្រឹត្តិការណ៍ឬសកម្មភាព តាមគ្រប់ទម្រង់ និងគ្រប់មធ្យោបាយ។

**មាត្រា១៩ ..**

ហាមឃាត់ការផលិត ការនាំចូលឧបករណ៍អេឡិកត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ បឺត ហឺត ស្រូប និងស៊ីស្សាគ្រប់ប្រភេទ។

## ជំពូកទី៤
## ទណ្ឌកម្ម

**មាត្រា២០ ..**

បុគ្គលណាដែលប្រើប្រាស់ និង/ឬ កាន់កាប់ឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ បឺត ហឺត ស្រូប និងស៊ីស្សាគ្រប់ប្រភេទដូចមានចែងក្នុងមាត្រា១៦ ខាងលើ ត្រូវព្រមាន ណែនាំផ្ទាល់មាត់ និងដកហូត ឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ បឺត ហឺត ស្រូប និងស៊ីស្សា។

ករណីមិនរាងចាល ត្រូវដកហូតឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ បឺត ហឺត ស្រូប និងស៊ីស្សា ព្រមានជាលាយលក្ខណ៍អក្សរ និងធ្វើកិច្ចសន្យាឈប់ប្រើប្រាស់។

**មាត្រា២១ ..**

បុគ្គលណាដែលបានចែកចាយ លក់ ស្តុកទុក ផ្សព្វផ្សាយពាណិជ្ជកម្ម ផ្សព្វផ្សាយលក់ ផលិត និង/ឬ នាំចូលឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ បឺត ហឺត ស្រូប និងស៊ីស្សា តាមមធ្យោបាយណាក៏ដោយដូចមានចែងក្នុងមាត្រា១៧ មាត្រា១៨ និងមាត្រា១៩ ខាងលើ ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដកហូតឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ បឺត ហឺត ស្រូប និងស៊ីស្សា និងព្យួរវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្ម អាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្មដែលចេញដោយក្រសួង ស្ថាប័ន ឬអាជ្ញាធរពាក់ព័ន្ធ។

ករណីមិនរាងចាលដោយបន្តចែកចាយ លក់ ស្តុកទុក ផ្សព្វផ្សាយពាណិជ្ជកម្ម ផ្សព្វផ្សាយលក់ ផលិត និង/ឬនាំចូលឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ បឺត ហឺត ស្រូប និងស៊ីស្សា ត្រូវដកហូតឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ បឺត ហឺត ស្រូប និងស៊ីស្សា និងលុបចោលវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម អាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម។

**មាត្រា២២ ..**

ការសម្រេចដាក់ទណ្ឌកម្មស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ មិនមែនជាឧបសគ្គដល់ការចោទប្រកាន់ និងផ្តន្ទាទោសព្រហ្មទណ្ឌ ព្រមទាំងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ជាធរមានឡើយ។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា២៣ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២៤ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ខែ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**រដ្ឋមន្ត្រី**
**ក្រសួងសុខាភិបាល**

សាស្ត្រាចារ្យ **ឈាង រ៉ា**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

**កំណត់មូលហេតុសង្ខេប**
**អំពី**
**សេចក្តីព្រាងអនុក្រឹត្យស្តីពី**
**វិធានការហាមឃាត់ការនាំចូល ការចែកចាយ ការលក់ ការផ្សាយពាណិជ្ជកម្ម**
**ការប្រើប្រាស់ ការកាន់កាប់ ការផលិត និងការស្តុកទុកឧបករណ៍អេឡិចត្រូនិក**
**និងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្សា**

សូមគោរពសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់!

សូមគោរពឯកឧត្តម ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាទីគោរព

សូមគោរព ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ឯកឧត្តមទេសរដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវរដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គប្រជុំទាំងមូល!

ជាបឋម ខ្ញុំបាទមានកិត្តិយសសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាដែលបានអនុញ្ញាតឱ្យដាក់សេចក្តីព្រាងអនុក្រឹត្យស្តីពីវិធានការហាមឃាត់ការនាំចូល ការចែកចាយ ការលក់ ការផ្សាយពាណិជ្ជកម្ម ការប្រើប្រាស់ ការកាន់កាប់ ការផលិត និងការស្តុកទុកឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្សា ក្នុងរបៀបវារៈនៃកិច្ចប្រជុំជំនាញបច្ចេកទេស ដើម្បីពិនិត្យ ពិភាក្សា និងផ្តល់យោបល់នាពេលនេះ។ ប្រការនេះបញ្ជាក់ពីការយកចិត្តទុកដាក់ចំពោះការលើកកម្ពស់សុខភាពនិងសុខុមាលភាពរបស់អ្នកសិក្សានិងបុគ្គលិកអប់រំដែលជាកូនសោគន្លឹះក្នុងការអភិវឌ្ឍធនធានមនុស្ស ប្រកបដោយសក្តានុពល ដើម្បីចូលរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមជាតិ។

ការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីវិធានការហាមឃាត់ការនាំចូល ការចែកចាយ ការលក់ ការផ្សាយពាណិជ្ជកម្ម ការប្រើប្រាស់ ការកាន់កាប់ ការផលិត និងការស្តុកទុកឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្សា គឺតម្រូវទៅតាមបរិបទសាកលភាវូបនីយកម្មនិងការរីកចម្រើនផ្នែកបច្ចេកវិទ្យា ដែលមានលេចចេញនូវឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់និងស៊ីស្សា ដែលមានហានិភ័យខ្ពស់សម្រាប់សុខភាព និងពុំទាន់មានវិធានសម្រាប់គ្រប់គ្រងនិងប្រើប្រាស់ឱ្យបានច្បាស់លាស់នៅឡើយទេ។ មូលដ្ឋាននៃការរៀបចំ មានដូចខាងក្រោម៖

## ១. ការអនុវត្តគោលការណ៍និងគោលនយោបាយ

- យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ កោណទី១ "ការអភិវឌ្ឍមូលធនមនុស្ស" ត្រង់ មុំទី១ "ការពង្រឹងវិស័យអប់រំ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា" ដែលជាទិភាពសំខាន់មួយក្នុងចំណោមអាទិភាពទាំង៧ ត្រូវដោះស្រាយចំពោះមុខ។ វិធានការគន្លឹះសម្រាប់ដោះស្រាយចំនួន៨ នៅក្នុងការលើកកម្ពស់

គុណភាពអប់រំចាប់ពីកម្រិតមត្តេយ្យសិក្សាដល់មធ្យមសិក្សាបឋមភូមិ ក្នុងនោះមានការលើកកម្ពស់សុខភាពសិក្សា ការយកចិត្តទុកដាក់លើសុខភាពរបស់សិស្ស តាមរយៈកម្មវិធីអាហារូបត្ថម្ភដល់កុមារ និងការត្រួតពិនិត្យគុណភាពចំណីអាហារនៅតាមសាលារៀន ជាវិធានការគន្លឹះទី៣ ក្នុងចំណោមវិធានការគន្លឹះទាំង៤។ សុខភាពរបស់បុគ្គលិកអប់រំ និងអ្នកសិក្សាគឺជាកត្តាដ៏សំខាន់មួយដែលរួមចំណែកដល់ការធានាបាននូវការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព។

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៧២ បានកំណត់ថា **"សុខភាពរបស់ប្រជាពលរដ្ឋត្រូវបានធានា។ រដ្ឋយកចិត្តទុកដាក់ដល់ការការពារជំងឺនិងព្យាបាលជំងឺ។ ប្រជារាស្ត្រក្រីក្រ ត្រូវបានទទួលការពិនិត្យសុខភាពដោយឥតបង់ថ្លៃនៅតាមមន្ទីរពេទ្យ គិលានដ្ឋាន និងមន្ទីរសម្ភពសាធារណៈ។**
- ច្បាប់ស្តីពីការអប់រំ មាត្រា៤១ កំណត់អំពីសិទ្ធិរបស់អ្នកសិក្សានិងបុគ្គលិកអប់រំក្នុងការត្រួតពិនិត្យសុខភាពដែលមានខ្លឹមសារថា **"អ្នកសិក្សានិងបុគ្គលិកអប់រំនៃគ្រឹះស្ថានសិក្សាដែលមានអាជ្ញាបណ្ណអប់រំ មានសិទ្ធិទទួលបាននូវការពិនិត្យសុខភាព"**។
- គោលនយោបាយជាតិស្តីពីសុខភាពសិក្សាដែលបានជំរុញឱ្យគ្រប់ក្រសួង ស្ថាប័នដែលមានគ្រឹះស្ថានសិក្សាឱ្យយកចិត្តទុកដាក់ចំពោះសុខភាពរបស់អ្នកសិក្សានិងបុគ្គលិកអប់រំ សំដៅអភិវឌ្ឍធនធានមនុស្សឱ្យមានលក្ខណសម្បត្តិពេញលេញនិងមានសុខភាពល្អទាំងកាយសម្បទា បញ្ញា ស្មារតី ដើម្បីអភិវឌ្ឍសង្គមកម្ពុជាប្រកបដោយចីរភាព ឈានទៅសម្រេចគោលដៅអភិវឌ្ឍជាតិក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នាឆ្នាំ២០៣០ និងជាប្រទេសអភិវឌ្ឍន៍ពេញលេញនាឆ្នាំ២០៥០។
- **វិធានការចំពោះឧបករណ៍អេឡិចត្រូនិកសម្រាប់ជក់ដែលបានអនុវត្តកន្លងមក** ដែលក្រសួង ស្ថាប័នពាក់ព័ន្ធ បានដាក់ចេញ៖
    - អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានចេញសេចក្តីណែនាំលេខ០០១/១៤ សណន.អជបគញ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៤ ហាមឃាត់ការប្រើប្រាស់ ការធ្វើអាជីវកម្ម និងការនាំចូលផលិតផលស៊ីហ្សា(Sisha) និងបារីអេឡិចត្រូនិក (E-Cigarette) នៅក្នុងព្រះរាជាណាចក្រកម្ពុជា។
    - អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានចេញសេចក្តីណែនាំលេខ០០១/២១ សណន.អជបគញ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២១ ដាក់បញ្ចូលការហាមឃាត់ផលិតផលអេចឈ៍ ធី ភី (HTPs)។
    - ក្រសួងអប់រំ យុវជន និងកីឡា បានចេញសេចក្តីណែនាំលេខ២៦ អយក.សណន ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២២ ហាមឃាត់ការប្រើប្រាស់ ការចែកចាយ ការជួញដូរ ការផ្សាយពាណិជ្ជកម្មបារីអេឡិចត្រូនិកនិងផលិតផលអេចឈ៍ ធី ភី ខាងក្នុង និងជុំវិញបរិវេណគ្រឹះស្ថានសាធារណៈ និងឯកជន។
    - ក្រសួងទេសចរណ៍ បានចេញសេចក្តីណែនាំលេខ០០៦ សណន ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២២ ហាមឃាត់ការប្រើប្រាស់និងការចែកចាយលក់បារីអេឡិចត្រូនិក និងផលិតផលអេចឈ៍ ធី ភី នៅក្នុងមូលដ្ឋានទេសចរណ៍។

- អគ្គស្នងការនគរបាលជាតិ ស្នងការនគរបាលរាជធានី ខេត្ត និងសមត្ថកិច្ចពាក់ព័ន្ធ បានចាត់វិធានការលើអ្នកចែកចាយលក់បារីអេឡិចត្រូនិក ដោយរឹបអូសឧបករណ៍នេះនិងធ្វើកិច្ចសន្យាមិនឱ្យបន្តលក់ទៀត។
- ស្ថាប័នពាក់ព័ន្ធ ក៏បានអប់រំណែនាំអ្នកប្រើប្រាស់ឱ្យឈប់ប្រព្រឹត្តបន្តទៀត។

ប៉ុន្តែ ទោះបីជាមានសេចក្តីសេចក្តីណែនាំទាំងនេះ និងការចាត់វិធានការអន្តរាគមន៍ក៏ដោយ ក៏ការប្រើប្រាស់និងការបង្ហោះផ្សព្វផ្សាយលក់តាមបណ្តាញព័ត៌មាននូវឧបករណ៍អេឡិចត្រូនិកមិនបានថយចុះតាមការរំពឹងទុកនៅឡើយទេ។

## ២. ឧបករណ៍អេឡិចត្រូនិកសម្រាប់ជក់និងផលប៉ះពាល់

ឧបករណ៍អេឡិចត្រូនិកសម្រាប់ជក់ ជាផលិតផលញៀនប្រភេទថ្មី ដែលត្រូវផលិតឡើងដើម្បីទាក់ទាញកុមារ យុវជន និងស្ត្រីវ័យក្មេង តាមរយៈការរចនាឧបករណ៍នេះដូចរូបតុក្កតា ឬប្រដាប់ក្មេងលេង ប៊ិចផ្លាសកុំព្យូទ័រ គ្រឿងសម្អាងស្ត្រី និងប្រកបដោយពណ៌ស្រស់ស្អាត។ល។ ឧបករណ៍នេះ ប្រើថ្មពិលដើម្បីកម្តៅវត្ថុរាវ ស្លឹកថ្នាំជក់ ឬនិងសារធាតុផ្តល់រសជាតិនិងក្លិនផ្សេងទៀត ឱ្យក្លាយជាចំហាយសម្រាប់អ្នកជក់បឺតចូលក្នុងសួត។ ចំហាយចេញពីឧបករណ៍អេឡិចត្រូនិកសម្រាប់ជក់ ផ្ទុកសារធាតុនីកូទីន ភាគល្អិតតូចៗដែលស្រូបចូលយ៉ាងជ្រៅក្នុងសួត សារធាតុគីមីមានក្លិន ដូចជា Diacetyl ដែលបណ្តាលអោយមានជំងឺសួតធ្ងន់ធ្ងរ Benzene, Acetaldehyde, Formaldehyde បណ្តាលអោយកើតមហារីក និងក្រុមលោហៈធ្ងន់ ដូចជា នីកែល សំណ សំណប៉ាហាំង និងសារធាតុផ្តល់រសជាតិនិងក្លិន ដែលធ្វើឱ្យញៀននិងប៉ះពាល់ដល់សុខភាពយ៉ាងធ្ងន់ធ្ងរដល់អ្នកជក់និងអ្នកនៅជុំវិញ។

យោងតាមការបញ្ជាក់របស់អង្គការសុខភាពពិភពលោក និងស្ថាប័នសុខភាពធំៗ ការប្រើប្រាស់ឧបករណ៍អេឡិចត្រូនិកសម្រាប់ជក់ បង្កការខូចខាតដល់ការលូតលាស់របស់កុមារនិងយុវជន ដែលនាំឱ្យការចុះខ្សោយខួរក្បាល ហើយនឹងប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ការអភិវឌ្ឍមូលធនមនុស្សរបស់យើង។ មិនតែប៉ុណ្ណោះការប្រើប្រាស់ឧបករណ៍ប្រភេទនេះ ក៏បង្កឱ្យមានរបួសសួតធ្ងន់ធ្ងរ ដែលហៅថា EVALI (Electronic or Vaping Use-associated Lung Injuries) និងសរីរាង្គមួយចំនួនទៀត ដូចជាបេះដូង ថ្លើម និងតម្រងនោម។ ក្រៅពីនោះ ឧបករណ៍នេះក៏អាចប្រើសម្រាប់ជក់គ្រឿងញៀនហាមឃាត់ផ្សេងទៀតបានដែរ ជាហេតុជំរុញឱ្យមានការប្រើប្រាស់គ្រឿងញៀនក្នុងចំណោមកុមារនិងយុវជន។ ការផ្ទុះថ្មពិលក្នុងឧបករណ៍អេឡិចត្រូនិកសម្រាប់ជក់ ធ្វើឱ្យរលាកអ្នកប្រើប្រាស់ជាពិសេសមុខនិងភ្នែក។ ក្រៅពីនេះ វាក៏បណ្តាលអោយថយចុះនៃការផ្តង់អារម្មណ៍ ការរៀនសូត្រ ការគ្រប់គ្រងកំហឹង ហើយស្តែងចេញជាភាពមួរម៉ៅ រសាប់រសល់ ថប់អារម្មណ៍ ឬអស់សង្ឃឹម វិបត្តិនៃការគេង និងសន្ទុះចិត្តចង់ប្រើនីកូទីន។

អង្គការសុខភាពពិភពលោក បានបញ្ជាក់ថា ឧបករណ៍អេឡិចត្រូនិកសម្រាប់ជក់ មិនមែនជាម៉ាស៊ីនផ្តាច់បារីទេ ប៉ុន្តែកុមារនិងយុវជនដែលជក់ឧបករណ៍នេះ មានទំនោរបីដង ទៅបួនដងក្លាយជាអ្នកជក់បារី នៅពេលចម្រើនវ័យ ជាងអ្នកដែលមិនធ្លាប់ប្រើប្រាស់ឧបករណ៍នេះ។

## ៣. ស្ថានភាពនៃការប្រើប្រាស់ឧបករណ៍អេឡិចត្រូនិកសម្រាប់ជក់

ការប្រើប្រាស់ឧបករណ៍អេឡិចត្រូនិកសម្រាប់ជក់ កំពុងរីករាលដាលគួរអោយព្រួយបារម្ភក្នុងចំណោមកុមារនិងយុវជន។ នៅក្នុងកិច្ចប្រជុំមួយដែលរៀបចំដោយក្រសួងអប់រំ យុវជននិងកីឡា នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៤ នាយកឬតំណាងគ្រឹះស្ថានមធ្យមសិក្សាប្រមាណ១០០ ដែលបានចូលរួមក្នុងកិច្ចប្រជុំ សុទ្ធតែបានអះអាងថា សាលារបស់ខ្លួនកំពុងប្រឈមនឹងបញ្ហាសិស្សប្រើប្រាស់ឧបករណ៍អេឡិចត្រូនិកសម្រាប់ជក់។ តាមការសិក្សាបឋមមួយរបស់ក្រសួងអប់រំ យុវជន និងកីឡា បង្ហាញថា យុវជនអាយុ១៥ឆ្នាំទៅ៣៥ឆ្នាំ ចំនួន ១៣៥០នាក់ ដែលបានចូលរួមក្នុងការសិក្សា មាន៧% បានប្រាប់ថា គាត់ជាអ្នកប្រើប្រាស់ឧបករណ៍អេឡិចត្រូនិកសម្រាប់ជក់ ទោះបីគាត់ដឹងថាផលិតផលនេះត្រូវបានហាមឃាត់ក៏ដោយ។ ក្នុងនោះ អ្នកចូលរួមការសិក្សា៤០% បានអះអាងថា ពួកគាត់មានមិត្តភក្តិម្នាក់យ៉ាងតិច ជាអ្នកប្រើប្រាស់ឧបករណ៍អេឡិចត្រូនិកសម្រាប់ជក់ ហើយ៨៥%នៃអ្នកប្រើប្រាស់ឧបករណ៍អេឡិចត្រូនិកសម្រាប់ជក់ មានមុខរបរជាសិស្សនិងនិស្សិត និងមានអាយុពី១៥ឆ្នាំទៅ២៩ឆ្នាំ។ ថ្វីត្បិតតែអ្នកប្រើប្រាស់ភាគច្រើនជាសិស្សនិងនិស្សិត ប៉ុន្តែពួកគាត់ភាគច្រើនលើសលប់មិនប្រើប្រាស់ឧបករណ៍អេឡិចត្រូនិកសម្រាប់ជក់ នៅខាងក្នុងបរិវេណ ឬជុំវិញគ្រឹះស្ថានសិក្សាទេ។ ទីកន្លែងដែលពួកគាត់ប្រើប្រាស់ឧបករណ៍អេឡិចត្រូនិកសម្រាប់ជក់ញឹកញាប់ គឺនៅហាងកាហ្វេ/ភោជនីយដ្ឋាន សួនសាធារណៈ ក្លឹបកម្សាន្ត ផ្ទះ និងដងផ្លូវ។ អ្នកប្រើប្រាស់ឧបករណ៍អេឡិចត្រូនិកសម្រាប់ជក់ច្រើនលើសលប់ បញ្ជាទិញឧបករណ៍នេះតាមការបង្ហោះលក់នៅតាមបណ្តាញព័ត៌មានសង្គម ដូចជា Tik Tok, Facebook, Telegram។

## ៤. ការរៀបចំសេចក្តីព្រាងអនុក្រឹត្យ

ក្រសួងអប់រំ យុវជន និងកីឡា បានសហការជាមួយក្រសួងសុខាភិបាល ក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធ ដោយបង្កើតក្រុមការងាររៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីវិធានការហាមឃាត់ការនាំចូល ការចែកចាយ ការលក់ ការផ្សាយពាណិជ្ជកម្ម ការប្រើប្រាស់ ការកាន់កាប់ ការផលិត និងការស្តុកទុកឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្សា ដើម្បីសម្រេចបាននូវគោលបំណងនិងភាពចាំបាច់ ដូចខាងក្រោម៖

- លើកកម្ពស់សុខភាពអ្នកសិក្សា បុគ្គលិកអប់រំ និងសុខភាពសាធារណៈ ដោយរៀបចំយន្តការនិងវិធានការទប់ស្កាត់រាល់សកម្មភាព ឬរូបភាពណាមួយដែលបង្កគ្រោះថ្នាក់ដោយផ្ទាល់ ឬដោយប្រយោល សំដៅការពារអ្នកសិក្សានិងបុគ្គលិកអប់រំឱ្យមានសុខភាពល្អ មានសុវត្ថិភាពទាំងនៅក្នុងគ្រឹះស្ថានសិក្សា គ្រួសារ និងសង្គម
- **ភាពចាំបាច់នៃការរៀបចំអនុក្រឹត្យនេះ មាន៖**
    - ការប្រើប្រាស់ឧបករណ៍អេឡិចត្រូនិកសម្រាប់ជក់ កំពុងរីករាលដាលគួរអោយព្រួយបារម្ភ ក្នុងចំណោមកុមារនិងយុវជន មិនថានៅរាជធានី ឬនៅបណ្តាខេត្ត
    - ការប្រើប្រាស់ឧបករណ៍អេឡិចត្រូនិកសម្រាប់ជក់ បណ្តាលអោយមានការប៉ះពាល់យ៉ាងខ្លាំងដល់មូលធនមនុស្សជំនាន់ក្រោយរបស់កម្ពុជា ព្រោះចំហាយចេញពីឧបករណ៍អេឡិចត្រូនិកសម្រាប់ជក់ផ្ទុកសារធាតុញៀន និងសារធាតុបង្កគ្រោះថ្នាក់ ដែលបង្អាក់ដល់ការលូតលាស់ខួរក្បាល និងបំផ្លាញសុខភាពជាទម្ងន់ដល់កុមារនិងយុវជន។

- ឧបករណ៍អេឡិចត្រូនិកសម្រាប់ជក់ អាចជាច្រកទ្វារទៅកាន់ការរីករាលដាលនៃការប្រើប្រាស់គ្រឿងញៀន ព្រោះឧបករណ៍នេះ ក៏អាចប្រើសម្រាប់ជក់គ្រឿងញៀនខុសច្បាប់ផ្សេងទៀតផងដែរ។
- អនុសាសន៍របស់អង្គការសុខភាពពិភពលោក ឱ្យរដ្ឋជាសមាជិកយកចិត្តទុកដាក់ទប់ស្កាត់ការប្រើប្រាស់ឧបករណ៍អេឡិចត្រូនិកសម្រាប់ជក់ ហើយវិធានការមានប្រសិទ្ធភាពបំផុត គឺការហាមឃាត់ការប្រើប្រាស់ រួមទាំងការផលិតនិងការនាំចូលឧបករណ៍នេះ។
- មានប្រទេស៦ ក្នុងតំបន់អាស៊ាន ដែលបានហាមឃាត់ឧបករណ៍អេឡិចត្រូនិកសម្រាប់ជក់ រួមមាន ប្រ៊ុយណេ ឡាវ ថៃ សិង្ហបុរី វៀតណាម និងកម្ពុជា។ ប្រទេសដែលនៅសល់កំពុងរៀបចំច្បាប់ឬបទដ្ឋានគតិយុត្តដើម្បីហាមឃាត់ឬដាក់កំហិតការប្រើប្រាស់ឧបករណ៍នេះ។

សេចក្តីព្រាងអនុក្រឹត្យនេះ បានឆ្លងកាត់ប្រជុំបច្ចេកទេសជាច្រើនលើក និងកិច្ចប្រជុំអន្តរក្រសួងស្តីពីសុខភាពសិក្សា នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២៤ ដែលដឹកនាំកិច្ចប្រជុំដោយឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងមានការចូលរួមពីតំណាងគណៈរដ្ឋមន្ត្រី ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ ថ្នាក់ដឹកនាំក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត និងអ្នកជំនាញ សរុបចំនួន ៩៤រូប។ សមាជិកនៃកិច្ចប្រជុំ បានបង្ហាញនូវក្តីកង្វល់នៃការរីករាលដាលការប្រើប្រាស់ឧបករណ៍អេឡិចត្រូនិកសម្រាប់ជក់និងសារធាតុគីមី និងស៊ីស្សាជាពិសេសក្នុងចំណោមកុមារនិងយុវវ័យ និងគាំទ្រនូវការផ្តួចផ្តើមអនុក្រឹត្យនេះ ដើម្បីដោះស្រាយបញ្ហាចាំបាច់នេះ ជាបន្ទាន់។

## ៥. ខ្លឹមសារសង្ខេប

សេចក្តីព្រាងអនុក្រឹត្យស្តីពីវិធានការហាមឃាត់ការនាំចូល ការចែកចាយ ការលក់ ការផ្សាយពាណិជ្ជកម្ម ការប្រើប្រាស់ ការកាន់កាប់ ការផលិត និងការស្តុកទុកឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្សា មាន៥ជំពូក និង២៤មាត្រា ដែលមានសេចក្តីសង្ខេបដូចខាងក្រោម៖

-ជំពូកទី១ បទប្បញ្ញត្តិទូទៅ វិសាលភាព និងនិយមន័យ ដែលមាន៣មាត្រា។

-ជំពូកទី២ កំណត់អំពី ស្ថាប័នមានសមត្ថកិច្ច ដែលមាន១២មាត្រា។

-ជំពូកទី៣ កំណត់អំពី ការហាមឃាត់ ដែលមាន៤មាត្រា

-ជំពូកទី៤ កំណត់អំពី ទណ្ឌកម្ម ដែលមាន៣មាត្រា។

-ជំពូកទី៥ កំណត់អំពី អវសានប្បញ្ញត្តិ ដែលមាន២មាត្រា។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ ខ្ញុំបាទសូម **សម្តេចមហាបវរធិបតី** ឯកឧត្តម លោកជំទាវ លោក លោកស្រី មេត្តាជួយផ្តល់អនុសាសន៍ និងយោបល់ដោយសេចក្តីអនុគ្រោះ។

**សូមអរគុណ!**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កំណត់ហេតុកិច្ចប្រជុំ
# គណៈកម្មាធិការអន្តរក្រសួងស្តីពីសុខភាពសិក្សា
# ដើម្បីស្វែងរកវិធានការដើម្បីបង្ការនិងទប់ស្កាត់ការប្រើប្រាស់
# និងចែកចាយបារីអេឡិចត្រូនិកចំណោមយុវជន

ថ្ងៃអង្គារ ៧រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៤ វេលាម៉ោង ៨:៣០នាទីព្រឹក នៅសណ្ឋាគារសាន់វេ រាជធានីភ្នំពេញ គណៈកម្មាធិការអន្តរក្រសួងស្តីពីសុខភាពសិក្សា ដែលហៅកាត់ថាគ.អ.ស.ស. បានរៀបចំកិច្ចប្រជុំវិសាមញ្ញ ក្រោមអធិបតីភាពដឹកនាំដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ ជួន ណារ៉ុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងជាប្រធានគ.អ.ស.ស.។ កិច្ចប្រជុំនេះមានការចូលរួមពីឯកឧត្តម លោកជំទាវ មកពីក្រសួង ស្ថាប័នពាក់ព័ន្ធរួមមាន ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងសុខាភិបាល ក្រសួងធម្មការនិងសាសនា ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងការពារជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងពាណិជ្ជកម្ម ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រសួងផែនការ ក្រសួងពាណិជ្ជកម្ម ក្រសួងព័ត៌មាន ក្រសួងយុត្តិធម៌ ក្រសួងអធិការកិច្ច ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងទេសចរណ៍ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងកិច្ចការនារី ក្រសួងមុខងារសាធារណៈ សមាជិក សមាជិកានៃគ.អ.ស.ស. និងឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានី ខេត្តទាំងអស់ ជាសមាជិកនៃគ.អ.ស.ស. ព្រមទាំងឯកឧត្តម លោកជំទាវ លោក លោកស្រីតំណាងអញ្ជើញមកពីអគ្គស្នងការនគរបាលជាតិ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យានៃក្រសួងមហាផ្ទៃ ថ្នាក់ដឹកនាំនៃលេខាធិការដ្ឋាននគ.អ.ស.ស. អង្គការចលនាដើម្បីសុខភាពកម្ពុជា និងតំណាងដៃគូអភិវឌ្ឍសរុបចំនួន៧២រូប ស្រី២១រូប។

កិច្ចប្រជុំបានប្រព្រឹត្តទៅតាមការគ្រោងទុកតាមរបៀបវារៈចំនួន៥រួមមាន៖

១- របាយការណ៍សង្ខេបការស្តីពីលទ្ធផលនៃការស្រាវជ្រាវការបង្ការទប់ស្កាត់ហានិភ័យផ្នែកសុខភាពសិក្សា បង្កដោយការប្រើប្រាស់និងចែកចាយបារីអេឡិចត្រូនិកក្នុងចំណោមយុវជន ដោយលោកជំទាវបណ្ឌិត សឿ សុជាតា អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា និងជាប្រធានលេខាធិការដ្ឋានគណៈកម្មាធិការអន្តរក្រសួងស្តីពីសុខភាពសិក្សា។

២- មតិសំណេះសំណាល អនុសាសន៍តម្រង់ទិស និងការប្រកាសបើកកិច្ចប្រជុំ ដោយឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា និងជាប្រធានគណៈកម្មាធិការអន្តរក្រសួងស្តីពីសុខភាពសិក្សា។

៣- បទបង្ហាញលទ្ធផលសង្ខេបការសិក្សាស្រាវស្រាវ ស្តីពីការបង្ការទប់ស្កាត់ហានិភ័យផ្នែកសុខភាពបង្កដោយការប្រើប្រាស់ និងចែកចាយបារីអេឡិចត្រូនិកក្នុងចំណោមយុវជន ដោយលោកវេជ្ជបណ្ឌិត យង់ គន្ធារិទ្ធ អនុប្រធាននាយកដ្ឋានសុខភាពសិក្សានិងជាអនុប្រធានលេខាធិការដ្ឋានគណៈកម្មាធិការអន្តរក្រសួងស្តីពីសុខភាពសិក្សា។

៤- បទបង្ហាញពីផលប៉ះពាល់នៃបារីអេឡិចត្រូនិក ដោយលោកវេជ្ជបណ្ឌិត មុំ គង់ នាយកប្រតិបត្តិអង្គការចលនាដើម្បីសុខភាពកម្ពុជា។

៥- ការដឹកនាំកិច្ចពិភាក្សាស្វែងរកវិធានការទប់ស្កាត់ និងបង្ការការប្រើប្រាស់បារីអេឡិចត្រូនិក និងបូកសរុប ប្រកាសបិទកិច្ចប្រជុំ ដោយលោកជំទាវ គឹម សេង្ហានី រដ្ឋលេខាធិការប្រចាំការ ក្រសួងអប់រំ យុវជន និងកីឡា និងជាអនុប្រធានប្រចាំការគណៈកម្មាធិការអន្តរក្រសួងស្តីពីសុខភាពសិក្សា។

ដូចការគ្រោងទុកក្នុងរបៀបវារៈខាងលើ ជាកិច្ចចាប់ផ្តើម លោកជំទាវ សឿ សុជាតា អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា និងជាប្រធានលេខាធិការដ្ឋានគ.អ.ស.ស.បានអានរបាយការណ៍សង្ខេបស្តីពីដំណើរការនៃការស្រាវជ្រាវការបង្ការទប់ស្កាត់ហានិភ័យផ្នែកសុខភាពសិក្សាបង្កដោយការប្រើប្រាស់និងចែកចាយបារីអេឡិចត្រូនិកក្នុងចំណោមយុវជន ដោយបានសង្កត់ធ្ងន់ថា ផ្អែកតាមលទ្ធផលនៃការសិក្សា ប្រសិទ្ធភាពនៃការបង្ការបញ្ឈប់ការប្រើប្រាស់ ការធ្វើអាជីវកម្មផលិតផលបារីអេឡិចត្រូនិក/វេបកន្លងមក ពិតជានៅមានកម្រិតនិងកំពុងជួបការប្រឈមពាក់ព័ន្ធទៅនឹងប្រព័ន្ធគ្រប់គ្រងលំហូរចូលនៃផលិតផលបារីអេឡិចត្រូនិក/វេប ឧបករណ៍ប្រើប្រាស់បារីអេឡិចត្រូនិកគ្រប់ប្រភេទ ដែលជាឧបករណ៍អាចប្រើជាមួយគ្រឿងញៀនបាន និងយន្តការពិនិត្យតាមដាន ក៏ដូចជាទោសទណ្ឌនានា ដែលក្រុមការងារសិក្សាស្រាវជ្រាវគោរពស្នើសុំការអនុញ្ញាតធ្វើការផ្សព្វផ្សាយលទ្ធផលនៃការសិក្សាស្រាវជ្រាវនាពេលនេះ។

ជាកិច្ចបន្ត ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងជាប្រធានគណៈកម្មាធិការអន្តរក្រសួងស្តីពីសុខភាពសិក្សា បានមានប្រសាសន៍ថ្លែងអំណរគុណចំពោះវត្តមានចូលរួមរបស់ឯកឧត្តម លោកជំទាវ អនុប្រធាន សមាជិក សមាជិកនៃគ.អ.ស.ស.និងមន្ត្រីអមដំណើរ ព្រមទាំងដៃគូក្រសួង ស្ថាប័ន អង្គភាព និងដៃគូអភិវឌ្ឍពាក់ព័ន្ធដែលបានអញ្ជើញចូលរួមកិច្ចប្រជុំដ៏មានសារសំខាន់នេះ។ ឯកឧត្តមបានគូសបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជា បានយល់ឃើញពីហានិភ័យដែលបង្កឡើងដោយបារីអេឡិចត្រូនិក ដូច្នេះហើយទើបបានចេញសេចក្តីណែនាំនានា ហើយចាត់ទុកបារីអេឡិចត្រូនិក/វេបនេះជាជាប្រភេទគ្រឿងញៀនមួយប្រភេទ ហើយធ្វើការហាមឃាត់ការចែកចាយនិងលក់ដូរផងដែរ។ ឯកឧត្តមបានបន្ថែមទៀតថា បារីធម្មតាមានផលប៉ះពាល់ខ្លាំងដល់សុខភាពសាធារណៈ ដូច្នេះរដ្ឋាភិបាលតម្រូវឱ្យក្រុមហ៊ុនបារីត្រូវភ្ជាប់សារព្រមានសុខភាពលើកញ្ចប់បារី ដោយឡែកបារីអេឡិចត្រូនិកប៉ះពាល់ដល់សុខភាពខ្លាំងជាងបារីធម្មតាទៅទៀត ជាពិសេសចំពោះកុមារនិងយុវជន ដោយបារីអេឡិចត្រូនិកនេះមានរូបរាងថ្មីៗទាក់ទាញ មានក្លិនក្រអូប ដែលនាំឱ្យកុមារនិងយុវជនយើងចង់សាក ចង់ដឹង ហើយក្លាយជាញៀន។ ដូចនេះយើងជួបជុំគ្នាថ្ងៃនេះ ដើម្បីរៀបចំនិងរិះរកវិធានការ ទប់ស្កាត់ និងបង្ការកុមារនិងយុវជនរបស់យើងពីការប្រើប្រាស់បារីអេឡិចត្រូនិកប្រកបដោយប្រសិទ្ធភាពជាងមុន។ មុននឹងផ្ទេរភារកិច្ចជូនលោកជំទាវ គឹម សេង្ហានី រដ្ឋលេខាធិការប្រចាំការក្រសួងអប់រំ យុវជន និងកីឡា និងជាអនុប្រធានប្រចាំ

ការគ.អ.ស.ស. ដឹកនាំសម្របសម្រួលកិច្ចប្រជុំបន្ត ឯកឧត្តមបណ្ឌិតសភាចារ្យបានផ្តល់អនុសាសន៍មួយចំនួនទៅអង្គប្រជុំដើម្បីធ្វើការពិភាក្សានិងពិចារណាដូចខាងក្រោម៖

១- ត្រូវពិនិត្យកែសម្រួលរបាយការណ៍ឡើងវិញដើម្បីជានាសង្គតិភាពទិន្នន័យ និងចៀសវាងការកើនច្រឡំបកស្រាយមិនច្បាស់លាស់។

២- ពង្រឹងការអប់រំផ្សព្វផ្សាយដោយប្រើប្រាស់យន្តការក្រុមប្រឹក្សាកុមារ និងក្រុមប្រឹក្សាយុវជននៅតាមសាលារៀនតាមរយៈការប្រជុំអប់រំ ការផ្សព្វផ្សាយការហាមឃាត់ការប្រើប្រាស់បារីអេឡិចត្រូនិក ការដាក់ស្លាកសញ្ញាស្តីពីផលប៉ះពាល់នៃបារីអេឡិកត្រូនិកឱ្យបានទូលំទូលាយ ពិសេសផ្សព្វផ្សាយផលប៉ះពាល់នៃបារីអេឡិចត្រូនិកនៅតាមបណ្តាញសង្គមជាដើម។

៣- ប្រើប្រាស់យន្តការក្រុមប្រឹក្សាកុមារនិងក្រុមប្រឹក្សាយុវជន ក្នុងការឆែក និងរឹបអូសយកបារីអេឡិចត្រូនិកប្រសិនបើរកឃើញ នៅក្នុងបរិវេណសិក្សា។

៤- ស្នើសុំកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីហាមឃាត់ការលក់បារីអេឡិត្រូនិកជុំវិញសាលារៀន ហើយក្រសួងអប់រំ យុវជន និងកីឡា នឹងចេញសេចក្តីណែនាំថ្មីមួយបន្ថែមលើសេចក្តីណែនាំដែលមានស្រាប់ ដោយធ្វើការហាមឃាត់ការលក់ដូរ ប្រើប្រាស់បារីអេឡិកត្រូនិកជុំវិញសាលារៀន។

៥- ស្នើដាក់បញ្ចូលមេរៀនផលប៉ះពាល់នៃបារីអេឡិចត្រូនិកទៅក្នុងមុខវិជ្ជាអប់រំសុខភាព និងបញ្ចូលជាផ្នែកមួយក្នុងស្តង់ដាទី៤ត្រង់ចំណុចការលើកកម្ពស់សុខភាពសិក្សានៃស្តង់ដាសាលាគំរូ។

៦- ស្នើក្រសួងសុខាភិបាលធ្វើការសិក្សា និងបញ្ជាក់ពីផលប៉ះពាល់នៃបារីអេឡិកត្រូនិក ដល់កុមារនិងយុវជន ដោយផ្អែកលើករណីសិក្សារបស់អង្គការសុខភាពពិភពលោក និងឯកសារនានាបន្ថែមទៀត។

៧- គួរពិនិត្យលទ្ធភាពរៀបចំជាអនុក្រឹត្យមួយស្តីពីការត្រួតពិនិត្យបារីនេះ ព្រោះត្រឹមចេញសារាចរឬគោលការណ៍ណែនាំផ្សេងៗមិនគ្រប់គ្រាន់ទេ ការចេញអនុក្រឹត្យមានអានុភាពទូលំទូលាយដោយបន្ថែមឱ្យមានទោសទណ្ឌផ្សេងៗ ដើម្បីទប់ស្កាត់ការប្រើប្រាស់បារីអេឡិកត្រូនិកនេះមានប្រសិទ្ធិភាព។

មុននឹងដំណើរការកិច្ចពិភាក្សាក្រោមការដឹកនាំរបស់លោកជំទាវ **គឹម សេង្ហានី** រដ្ឋលេខាធិការប្រចាំការក្រសួងអប់រំ យុវជន និងកីឡា និងជាអនុប្រធានប្រចាំការគ.អ.ស.ស. ឯកឧត្តមវេជ្ជបណ្ឌិត **យង់ គន្ធារិទ្ធ** អនុប្រធាននាយកដ្ឋានសុខភាពសិក្សានិងជាអនុប្រធានលេខាធិការដ្ឋានគ.អ.ស.ស. បានធ្វើបទបង្ហាញលទ្ធផលសង្ខេបការសិក្សាស្រាវស្រាវស្តីពីការបង្ការទប់ស្កាត់ហានិភ័យផ្នែកសុខភាពបង្កដោយការប្រើប្រាស់ និងចែកចាយបារីអេឡិចត្រូនិកក្នុងចំណោមយុវជន ដោយគូសបញ្ជាក់ថា អ្នកចូលរួមផ្តល់សម្ភាសន៍៨២% ធ្លាប់បានឃើញមានអ្នកប្រើប្រាស់បារីអេឡិចត្រូនិក ភាគច្រើននៅហាងកាហ្វេ/ភោជនីយដ្ឋាន សួនសាធារណៈ ក្លឹបកំសាន្ត និងតាមដងផ្លូវ។ ម្យ៉ាងទៀតអ្នកចូលរួមផ្តល់សម្ភាសន៍ ៤០% បានអះអាងថា ពួកគេមានមិត្តភក្តិម្នាក់យ៉ាងតិចជាអ្នកជក់បារីអេឡិចត្រូនិក ក្នុងនោះ៧៥% មានមុខរបរជាសិស្ស/និស្សិត។ ជាពិសេសអ្នកចូលរួមផ្តល់សម្ភាសន៍៧% បានទទួលស្គាល់ថា ពួកគាត់ជាអ្នកប្រើប្រាស់បារីអេឡិចត្រូនិក ទោះបីផលិតផលនេះត្រូវបានហាមឃាត់ដោយរាជរដ្ឋាភិបាលក៏ដោយ ហើយ៨៦%នៃពួកគាត់ អាចរកបានបារីអេឡិចត្រូនិកពីការបញ្ជាទិញតាមអ្នកផ្សព្វផ្សាយលក់តាមអនឡាញ។

បន្តមកទៀត ដើម្បីឱ្យយល់កាន់តែច្បាស់ពីបារីអេឡិចត្រូនិក លោកវេជ្ជបណ្ឌិត **មុំ គង់** បានធ្វើបទបង្ហាញពីផលប៉ះពាល់នៃការប្រើប្រាស់បារីអេឡិចត្រូនិក/វេប ដោយសង្កត់ធ្ងន់លើសារធាតុដែលមានក្នុងចំហាយបារីអេឡិចត្រូ

និក និងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សុខភាពអ្នកប្រើ ដែលភាគច្រើនជាកុមារនិងយុវជន។ ផលប៉ះពាល់ទាំងនោះ រួមមាន ធ្វើឱ្យអ្នកប្រើញៀនខ្លាំង ប៉ះពាល់ដល់ការអភិវឌ្ឍខួរក្បាល ធ្វើឱ្យមានរបួសសួតធ្ងន់ធ្ងរ (EVALI) ប៉ះពាល់ដល់បេះដូង ថ្លើម តម្រងនោម។ល។ ក្នុងបទបង្ហាញរបស់លោក បានផ្សារភ្ជាប់ជាមួយវីដេអូជនរងគ្រោះ និងយុវជនជក់បារីអេឡិចត្រូនិកផងដែរ។ លោកក៏បានបង្ហាញអំពីគណនីអនឡាញដែលសកម្មកំពុងបង្ហោះលក់បារីអេឡិចត្រូនិក/វេប ទាក់ទាញកុមារនិងយុវជន ដោយប្រើប្រាស់ល្បិចកលគ្រប់បែបយ៉ាង រួមមានការរចនារូបរាងទាក់ទាញ ក្លិន/រសជាតិសម្បូរបែប ពាក្យពេចន៍បោកបញ្ឆោត អួតបង្ហាញពីភាពឡូយឆាយ។ល។

បន្ទាប់ពីចប់បទបង្ហាញទាំងពីខាងលើ លោកជំទាវ គីម សេដ្ឋានី រដ្ឋលេខាធិការប្រចាំការក្រសួងអប់រំ យុវជន និងកីឡា និងជាអនុប្រធានប្រចាំការគ.អ.ស.ស. បានបន្តដឹកនាំសម្របសម្រួលកិច្ចប្រជុំ ដោយលោកជំទាវបានលើកលើកឡើងនូវសំណួរបំផុសមួយចំនួន សម្រាប់ការពិភាក្សាយោងជាបឋមលើអនុសាសន៍របស់ឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងជាប្រធានគ.អ.ស.ស.ជាអាទិ៍ ពិសេសការរៀបចំអនុក្រឹត្យគ្រប់គ្រងបារីអេឡិកត្រូនិក។ ត្រង់ចំណុចនេះ លោកជំទាវបានបំផុសសំណួរថា តើស្ថាប័នណាជាអ្នកទទួលបន្ទុកនាំមុខដឹកនាំរៀបចំសេចក្តីព្រាងអនុក្រឹត្យ? បន្ថែមលើនេះ លោកជំទាវក៏បានបំផុសឱ្យសមាជិកសមាជិកាចូលរួមលើកឡើងពីវិធានការចំពោះមុខបន្ទាន់ រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែងដើម្បីបង្ការទប់ស្កាត់ការប្រើប្រាស់បារីអេឡិកត្រូនិកក្នុងចំណោមកុមារនិងយុវជនរបស់យើងដូចជា តើគួរធ្វើអ្វីខ្លះ និងធ្វើដូចម្តេច? ព្រមទាំងស្នើឱ្យមានការចូលរួមផ្តល់ព័ត៌មានបន្ថែមពីផលប៉ះពាល់អវិជ្ជមានពីការប្រើប្រាស់បារីអេឡិចត្រូនិកពីអ្នកជំនាញផងដែរ។ បន្ទាប់មកលោកជំទាវបានស្នើសុំមតិយោបល់ពីអង្គប្រជុំជាបន្តបន្ទាប់ដែលមានបរិយាយដូចខាងក្រោម៖

- ឯកឧត្តម ធូ ភា អភិបាលរងនៃគណៈអភិបាលខេត្តបាត់ដំបង មានប្រសាសន៍ឯកភាពទាំងស្រុងចំពោះអនុសាសន៍របស់ឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងជាប្រធានគ.អ។ស.ស. និងគាំទ្រឱ្យមានការរៀបចំអនុក្រឹត្យ ទើបអាជ្ញាធរថ្នាក់ក្រោមជាតិងាយស្រួលអនុវត្តប្រកបដោយប្រសិទ្ធភាព។ ឯកឧត្តមបន្ថែមថា បច្ចុប្បន្ននេះនៅខេត្តបាត់ដំបង មានអ្នកប្រើបារីអេឡិកត្រូនិកនេះចាប់ពី ១០ឆ្នាំ ទៅ៤៥ឆ្នាំ ករណីខ្លះអាជ្ញាធររកឃើញក្មេងជក់វេប ជក់គ្រឿងញៀន ចាប់ពីអាយុ៩ឆ្នាំក៏មាន ពិសេសនៅក្រុងបាត់ដំបងផ្ទាល់តែម្តង។ កន្លងមកអាជ្ញាធរគ្រប់ថ្នាក់បានសហការអប់រំផ្សព្វផ្សាយហើយ តែលទ្ធផលដូចយើងបានឃើញក្នុងការសិក្សាស្រាវជ្រាវអញ្ចឹង គឺមិនមានការស្រេកស្រុតទេ ហើយទំនោរហាក់កើនឡើងថែមទៀតផង ព្រោះការផ្សព្វផ្សាយតាមអនឡាញទាក់ទាញខ្លាំងដល់ក្រុមយុវជន។ ហេតុនេះ ការមានអនុក្រឹត្យគឺអាចដោះស្រាយបញ្ហាចំពោះមុខបាន។
- លោកជំទាវ ម៉ាន ចិន្តា រដ្ឋលេខាធិការក្រសួងកិច្ចការនារី គាំទ្រឱ្យមានសារាចរ ឬអនុក្រឹត្យរបស់រាជរដ្ឋាភិបាលថ្មីមួយស្របតាមអនុសាសន៍ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។ ជាការកត់សម្គាល់របស់លោកជំទាវ អ្នកជក់វេបចាប់ពីអាយុ១០ឆ្នាំឡើងទៅ ច្រើនជាស្ត្រីជក់នៅតាមម៉លហើយជក់តាមមិត្តភក្តិ និងទិញតាមអនឡាញ។ ហេតុនេះ ការពង្រឹងវិធានការច្បាប់បន្ថែមទើបអាចដោះស្រាយចំពោះមុខបាន។

- ឯកឧត្តម **ទូច វិសាលសុខ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ មានប្រសាសន៍ទទួលស្គាល់លទ្ធផលនេះជាលទ្ធផលបឋម គួរប្រើតែនៅផ្ទៃក្នុងក្រុមការងារ និងមិនគួរផ្សព្វផ្សាយជាសាធារណៈនោះទេ ព្រោះវាអាចជះប៉ះពាល់មិនល្អដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកន្លងមក។ ឯកឧត្តមបន្ថែមថា គួរមានការសិក្សាលម្អិតបន្ថែមចំពោះអ្នកជក់ផ្ទាល់ ថាតើមូលហេតុអ្វីបានជាគាត់ជក់? ដោយឡែកចំពោះក្លិនរសជាតិសំយោគ ក្នុងនាមឯកឧត្តមជាអ្នកគីមីមួយរូបដែរ ថាបើយើងហាមគេមិនឱ្យដាក់ក្លិនរសជាតិក្នុងផលិតផល គឺវាអាចប៉ះពាល់ដល់ផលិតផលមួយចំនួនទៀតដែរដូចជាអាហារស្របច្បាប់ដទៃទៀត ឧទាហរណ៍ ការហ្វេដូង គេមិនដាក់ដូងមែនទែនទេគឺគេដាក់ក្លិនដូងឈ្មុយធ្វើឱ្យយើងចង់ភ្លក់ជាប់មាត់ តែប្រការសំខាន់គឺទំនិញណាដែលរដ្ឋហាមឃាត់យើងគួរបញ្ជាក់ឱ្យច្បាស់។ ឯកឧត្តមបន្ថែមថា ប្រសិនបើយើងចង់ពង្រឹងការអនុវត្តច្បាប់ យើងគួរតែពិនិត្យឱ្យច្បាស់លើខ្លឹមសារច្បាប់ តើផលិតផលដែលមានចែងក្នុងច្បាប់យើងងាយស្រួលអនុវត្ត។
- ឯកឧត្តម **នួន ផារ័ត្ន** អភិបាលរងនៃគណៈអភិបាលរាជធានីភ្នំពេញ គាំទ្រឱ្យរដ្ឋាភិបាលចេញអនុក្រឹត្យហាមឃាត់បារីអេឡិចត្រូនិក ទើបអាជ្ញាធរមានសមត្ថកិច្ចនៅមូលដ្ឋានងាយស្រួលអនុវត្ត ព្រោះបើចុះចាប់គេត្រូវផ្អែកលើមូលដ្ឋានច្បាប់ច្បាស់លាស់។ ដោយឡែក អាជ្ញាធរមានសមត្ថកិច្ចគួរគិតពីការហាមលក់តាមអនឡាញបើយល់ថាបារីអេឡិកត្រូនិកប៉ះពាល់ដល់សុខភាពសាធារណៈធ្ងន់ធ្ងរ ហើយកិច្ចការនេះត្រូវការកិច្ចសហការជាមួយប៉ូលីសបច្ចេកវិទ្យាដើម្បីចាប់អ្នកលក់។
- ឯកឧត្តមសាស្ត្រាចារ្យ **យិត ស៊ុនណារ៉ា** រដ្ឋលេខាធិការក្រសួងសុខាភិបាល មានប្រសាសន៍ថា ឯកឧត្តមឯកភាពគួរមានអនុក្រឹត្យ ដើម្បីមានប្រសិទ្ធភាពអនុវត្ត ហើយក្រសួងសុខាភិបាលនៅតែខិតខំស្រាវជ្រាវបន្ថែមទៀត ដើម្បីប្រមូលផ្តុំ និងពញ្ញាក់អារម្មណ៍សាធារណជនពីគ្រោះថ្នាក់បារីអេឡិចត្រូនិក។ ក្រសួងសុខាភិបាលបានចាប់អារម្មណ៍បញ្ហានេះ តាំងពីអាជ្ញាធរជាតិចេញសេចក្តីណែនាំហាមឃាត់បារីអេឡិចត្រូនិកតាំងពីឆ្នាំ២០១៤មកម្ល៉េះ ហើយក្រសួងបានចេញសេចក្តីណែនាំពីផលប៉ះពាល់បារីអេឡិចត្រូនិកនៅខែ៦ ឆ្នាំ២០២២ ហើយថ្មីៗនេះ ក្រសួងបានចេញសេចក្តីណែនាំពីផលវិបាកនៃការប្រើប្រាស់បារីអេឡិចត្រូនិកផងដែរ។ ឯកឧត្តមបានបន្ថែមថា គ្រោះថ្នាក់ខ្លាំងគឺការផ្សាយលក់តាមបណ្តាញសង្គម ហើយកាលពីខែ៧ ឆ្នាំ២០២៣ ក្រសួងសុខាភិបាលបានធ្វើលិខិតមួយជូនទៅក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ដើម្បីជួយអន្តរាគមន៍ តែប្រសិទ្ធភាពនៅមានកម្រិត។ ក្រៅពីនេះ ក្រសួងបានចូលរួមបង្កើតវេទិកាសំណួរចម្លើយពីបារីអេឡិចត្រូនិក និងបានចេញ leaflet ស្តីពីផលប៉ះពាល់ដល់សុខភាពដោយសារការជក់បារីអេឡិកត្រូនិក ហើយបានផ្សព្វផ្សាយទូទាំងប្រទេស។ ជាចុងក្រោយ ក្នុងនាមក្រសួងសុខាភិបាលឯកឧត្តមអំពាវនាវឱ្យក្រសួងទាំងអស់ដែលស្ថិតក្នុងគណៈកម្មាធិការអន្តរក្រសួងស្តីពីសុខភាពសិក្សាឱ្យជួយអន្តរាគមន៍ព្រមៗគ្នា ដើម្បីដោះស្រាយផលវិបាកនៃការប្រើប្រាស់បារីអេឡិកត្រូនិក ព្រោះក្រសួងសុខាភិបាលតែឯងមិនអាចទៅរួចទេ។
- ឯកឧត្តម **អ៊ុល រ៉ី** រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានគាំទ្រឱ្យមានអនុក្រឹត្យ ព្រោះកិច្ចការនេះ ស្ថាប័នមួយមិនអាចធ្វើបានទេ ទាល់តែកម្រិតរាជរដ្ឋាភិបាលដែលមានដែនសមត្ថកិច្ចទូលាយជាង។ ឯកឧត្តមបានលើកឡើងថា គួរយកយន្តការគណៈកម្មការអន្តរក្រសួងស្តីពីសុខ

ភាពសិក្សាដែលមានស្រាប់ ឬក្រសួងអប់រំ យុវជន និងកីឡា ក្នុងការនាំមុខដឹកនាំធ្វើសេចក្ដីព្រាងអនុក្រឹត្យ ហើយក្រសួងពាក់ព័ន្ធនាំគ្នាស្រុះស្រួលគ្នាដើម្បីចូលរួមផ្ដល់យោបល់។

❖ លោកវរសេនីឯក តំណាងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានមានប្រសាសន៍ថា ពាក់ព័ន្ធបារីស៊ីសា និងបារីអេឡិចត្រូនិកនេះ មិនមានចែងក្នុងច្បាប់គ្រឿងញៀនទេ។ ដូចនេះ តំណាងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន សូមគាំទ្រឱ្យមានអនុក្រឹត្យដើម្បីទប់ស្កាត់ការប្រើប្រាស់បារីអេឡិចត្រូនិក។

❖ លោកស្រីឧត្តមសេនីត្រី តំណាងនាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា មានប្រសាសន៍គាំទ្រវិធានការផ្សព្វផ្សាយអប់រំ នៅតាមសាលារៀន និងដាក់បញ្ចូលក្នុងកម្មវិធីសិក្សា។ ចំពោះបញ្ហាបារីអេឡិចត្រូនិកនេះ មានការស្នើសុំឱ្យជួយបង្ក្រាប ហើយនាយកដ្ឋានបានអនុវត្តទៅតាមនីតិវិធីរបស់ខ្លួន។ នាយកដ្ឋានជួបបញ្ហាជាច្រើនដោយ មាន Fake Account ជាច្រើន មានន័យថា ពេលយើងដោះស្រាយគណនីចាស់ គេបង្កើតគណនីថ្មីរហូត។

❖ លោកជំទាវ **ប៉ែន សុបភា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានប្រសាសន៍ថា វិធានការកន្លងមក គ្រាន់តែមានសេចក្ដីណែនាំហាមឃាត់មួយចំនួនដែលចេញដោយស្ថាប័នមានសមត្ថកិច្ច យើងនៅខ្វះលិខិតគតិយុត្ត បង្ក្រាប ដាក់ទោសទណ្ឌ។ លោកជំទាវ ឯកភាពជាមួយក្រសួងសង្គមកិច្ច និងអតីតយុទ្ធជនក្នុងការឱ្យក្រសួងអប់រំ យុវជន និងកីឡា តាមរយៈយន្តការគណៈកម្មាធិការអន្តរក្រសួង ដឹកនាំរៀបចំសេចក្ដីព្រាងអនុក្រឹត្យ។ លោកជំទាវ ក៏បានចែករំលែកអំពីពន្ធនាំចូល បើយើងមើលនៅលើតារាងពន្ធនាំចូល មានអត្រា១៥% អាករពិសេស២៥% VAT ១០%។ ក៏ប៉ុន្តែ បើមានលិខិតគតិយុត្តហាមឃាត់ ទំនិញនេះ នឹងមិនមានការនាំចូលផលិតផលនេះទេ។

❖ ឯកឧត្តម **អ៊ិន វីរជាតិ** រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី បានធ្វើការពន្យល់កម្រងឯកសារច្បាប់ អនុក្រឹត្យប្រកាស និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងផលិតផលថ្នាំជក់ ក្នុងនោះឯកឧត្តមបានសង្កត់ធ្ងន់លើមាត្រា១៤ដែលបានចង្អុលត្រង់ឱ្យរៀបចំអនុក្រឹត្យ ដែលក្រសួងសុខាភិបាលដែលជាក្រសួងនាំមុខមិនទាន់បានរៀបចំនៅឡើង។ ហេតុនេះ ឯកឧត្តមបានស្នើសុំឱ្យនាយកដ្ឋាននីតិកម្មនៃក្រសួងសុខាភិបាលជាអ្នកផ្ដួចផ្ដើមរៀបចំសេចក្ដីព្រាងអនុក្រឹត្យ ដោយយោងទៅតាមច្បាប់ស្ដីពីការត្រួតពិនិត្យផលិតផលថ្នាំជក់ ដោយពង្រីកវិសាលភាពនិយមន័យ ឱ្យគ្របដណ្ដប់បារីអេឡិចត្រូនិក ហើយគណៈកម្មាធិការអន្តរក្រសួងស្ដីពីសុខភាពសិក្សានឹងផ្ដល់យោបល់បន្ថែម។ ឯកឧត្តម បានគូសបញ្ជាក់ដែរថា ក្នុងនាមឯកឧត្តមធ្វើការនៅទីស្ដីការគណៈរដ្ឋមន្ត្រីស្រាប់ ឯកឧត្តមអាចសម្របសម្រួលជាមួយក្រុមប្រឹក្សាអ្នកច្បាប់ដើម្បីពន្លឿនការពិនិត្យសេចក្ដីព្រាងអនុក្រឹត្យនេះ មុនដាក់ជូនសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី។

❖ ឯកឧត្តមសាស្ត្រាចារ្យ **យិត ស៊ុនណារ៉ា** រដ្ឋលេខាធិការក្រសួងសុខាភិបាល បានបង្ហាញពីការយល់ឃើញថា បារីអេឡិចត្រូនិកគួររៀបចំឡើងដោយអនុក្រឹត្យមួយដាច់ដោយឡែក ដោយមិនយោងតាមមាត្រា១៤នៃច្បាប់ស្ដីពីការត្រួតពិនិត្យផលិតផលថ្នាំជក់ទេ ព្រោះវិធានការលើបារីធម្មតា និងបារីអេឡិចត្រូនិក ខុសគ្នា បារីធម្មតាមានវិធានការបែបត្រួតពិនិត្យ រីឯបារីអេឡិចត្រូនិកគឺមានវិធានការហាមឃាត់ទាំងការប្រើប្រាស់ ចែកចាយ និងការនាំចូល។

❖ ឯកឧត្តម ប៉ាន ប៊ុនធឿន រដ្ឋលេខាធិការក្រសួងផែនការ បានមានប្រសាសន៍ថា ឯកឧត្តមឯកភាពលើអនុសាសន៍របស់ឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងជាប្រធានគ.អ.ស.ស. ហើយឯកឧត្តមលើកឡើងថា បើមិនយកច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់ទេ យើងគួរតែយកច្បាប់គ្រប់គ្រងគ្រឿងញៀន ដើម្បីផ្តួចផ្តើមរៀបចំសេចក្តីព្រាងអនុក្រឹត្យមួយនេះ។

❖ ឯកឧត្តម ឌុច ប៉ូលីវ៉ា អភិបាលរងគណៈអភិបាលខេត្តស្វាយរៀង មានយោបល់ថា យើងអាចធ្វើវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់ ដោយបន្ថែមនិយមន័យ និងបន្ថែមទោសទណ្ឌដល់អ្នកលក់ អ្នកផ្សព្វផ្សាយផលិតផលបារីអេឡិកត្រូនិក ដើម្បីឱ្យថ្នាក់ក្រោមជាតិស្រួលអនុវត្ត។ ឯកឧត្តម បានបញ្ជាក់ថា បារីអេឡិចត្រូនិកនេះ គ្មានផលល្អដល់សេដ្ឋកិច្ចយើងទេ។ ឯកឧត្តម សូមគាំទ្រអនុសាសន៍ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងស្នើសុំការបិទកុំឱ្យនាំចូលគ្រប់ច្រកនាំចូល ព្រោះ យើងអនុវត្តតែរឿងអប់រំ មិនមានប្រសិទ្ធភាពទេ ទាល់តែមានវិធានការច្បាប់ បិទការនាំចូលទើបដោះស្រាយបាន។

❖ លោកវេជ្ជបណ្ឌិត មុំ គង់ នាយកប្រតិបត្តិ អង្គការចលនាដើម្បីសុខភាពកម្ពុជា បានផ្តល់យោបល់ថា យោងតាមអង្គការសុខភាពពិភពលោក វិធានការលើបារីធម្មតា និងវិធានការលើបារីអេឡិចត្រូនិកគឺខុសគ្នា ដោយបារីធម្មតាគ្រាន់តែទាមទារការគ្រប់គ្រង ប៉ុន្តែបើបារីអេឡិចត្រូនិកគឺបិទតែម្តង។ បច្ចុប្បន្នបារីអេឡិចត្រូនិកត្រូវបានហាមឃាត់ទាំងការប្រើប្រាស់ ការចែកចាយលក់ ការនាំចូលជាដើម។ រីឯបារីធម្មតា បើយោងតាមច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់ គឺមិនបានហាមឃាត់ការប្រើប្រាស់ឬការលក់ដូរឡើយ។ ដូច្នេះ បើយើងយោងតាមមាត្រា១៨នៃច្បាប់ស្តីពីការត្រួតពិនិត្យថ្នាំជក់ ដើម្បីរៀបចំអនុក្រឹត្យហាមឃាត់ការប្រើប្រាស់ ការចែកចាយលក់ ការនាំចូលបារីអេឡិចត្រូនិក ខ្លាចក្រែងយើងមិនអាចហាមឃាត់បារីអេឡិចត្រូនិកបាន។ លោកក៏បានលើកបង្ហាញពីបទពិសោធន៍របស់ប្រទេសឡាវ ដែលគេបានធ្វើវិសោធន៍កម្មច្បាប់ថ្នាំជក់ ដោយបង្កើតជាមាត្រាថ្មីមួយសម្រាប់បារីអេឡិចត្រូនិក ដើម្បីរក្សាការហាមឃាត់ការប្រើប្រាស់ នាំចូលនិងចែកចាយ។

❖ មុននឹងបញ្ចប់លោកជំទាវ គឹម សេដ្ឋានី រដ្ឋលេខាធិការប្រចាំការនៃក្រសួងអប់រំ យុវជន និងកីឡា និងជាអនុប្រធានប្រចាំការគណៈកម្មាធិការអន្តរក្រសួងស្តីពីសុខភាពសិក្សាបានធ្វើការប្តូកសរុបលទ្ធផលការពិភាក្សាដូចខាងក្រោម៖

  ➢ សូមជូនលេខាធិការដ្ឋានគ.អ.ស.ស. និងអង្គការចលនាដើម្បីសុខភាពកម្ពុជា ដើម្បីពិនិត្យកែសម្រួលបន្ថែមលើលទ្ធផលសិក្សាស្រាវជ្រាវ ចៀសវាងការកែន្តប្រឡំទិន្នន័យចំពោះអ្នកប្រើប្រាស់ ហើយទិន្នន័យនេះគួររក្សាប្រើប្រាស់ផ្ទៃក្នុងគណៈកម្មាធិការអន្តរក្រសួងស្តីពីសុខភាពសិក្សា និងត្រូវស្នើសុំសេចក្តីសម្រេចពីឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងជាប្រធានគណៈកម្មាធិការអន្តរក្រសួងស្តីពីសុខភាពសិក្សា មុននឹងផ្សព្វផ្សាយជាសាធារណៈ។

- ក្រសួងអប់រំ យុវជន និងកីឡា នឹងបន្តអនុវត្តការអប់រំផ្សព្វផ្សាយពីផលប៉ះពាល់នៃបារីអេឡិចត្រូនិកបន្ថែមទៅក្នុងមុខវិជ្ជាអប់រំសុខភាព និងតាមរយៈក្រុមប្រឹក្សាកុមារនិងក្រុមប្រឹក្សាយុវជន ជាពិសេសផ្តោតក្នុងកម្រិតបឋមសិក្សានិងអនុវិទ្យាល័យ។
- ក្រសួងអប់រំ យុវជន និងកីឡា នឹងរៀបចំធ្វើបច្ចុប្បន្នភាពសេចក្តីណែនាំថ្មី ដោយកំណត់វិសាលភាពនៃការហាមឃាត់ការប្រើប្រាស់ និងការចែកចាយបារីអេឡិចត្រូនិកជុំវិញគ្រឹះស្ថានសិក្សា ដោយស្នើសុំកិច្ចសហការជាមួយអាជ្ញាធរពាក់ព័ន្ធ។
- សូមឱ្យរដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលក្រុង ស្រុក ខណ្ឌ មន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្ត ត្រូវបន្តអនុវត្តសេចក្តីណែនាំនានា របស់ក្រសួងអប់រំ យុវជន និងកីឡា និងសេចក្តីណែនាំនានារបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងបារីអេឡិចត្រូនិក។
- សូមឱ្យក្រសួងសុខាភិបាលនិងដៃគូពាក់ព័ន្ធគាំទ្រសិក្សាស្រាវជ្រាវបន្ថែមទៀតឱ្យបានស៊ីជម្រៅតាមបែបវិទ្យាសាស្ត្រ ដើម្បីបញ្ជាក់ឱ្យឃើញផលប៉ះពាល់ទៅលើសុខភាព និងសេដ្ឋកិច្ច នៃការប្រើប្រាស់បារីអេឡិចត្រូនិក។
- គណៈកម្មាធិការអន្តរក្រសួងស្តីពីសុខភាពសិក្សានឹងស្នើសុំគោលការណ៍ទៅរាជរដ្ឋាភិបាល ដើម្បីប្រគល់ភារកិច្ចជូនក្រសួងសុខាភិបាលដឹកនាំសម្របសម្រួលរៀបចំសេចក្តីព្រាងអនុក្រឹត្យថ្មីស្តីពីការហាមឃាត់ការប្រើប្រាស់ ការចែកចាយលក់ ការផលិត និងការនាំចូលបារី អេឡិចត្រូនិក ដោយផ្សារភ្ជាប់វិធានការទោសទណ្ឌដើម្បីធានាឱ្យវិធាននេះមានប្រសិទ្ធភាព។

អង្គប្រជុំបានចប់សព្វគ្រប់នៅវេលាម៉ោង១២ថ្ងៃត្រង់ នាថ្ងៃខែឆ្នាំដដែលប្រកបដោយជោគជ័យនិងស្មារតីភាតរភាព។

ថ្ងៃអង្គារ ៧រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៤

**ប្រធានលេខាធិការដ្ឋានគ.អ.ស.ស.**

បណ្ឌិត **សឿ សុជាតា**

**បានឃើញនិងឯកភាព**

**ប្រធានគ.អ.ស.ស.**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល
លេខ ០០៣៧ សនក

១០. សូមជូន៖ នា. សស

ថ្ងៃសុក្រ ១២ រោច ខែបឋមាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ វិច្ឆិកា ឆ្នាំ២០២៤

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**
**សូមគោរពជូន**
**ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងជាប្រធានគណៈកម្មាធិការអន្តរក្រសួង**
**ស្តីពីសុខភាពសិក្សា**

មកដល់ ថ្ងៃ ខែ ព.ស២៥
ថ្ងៃទី 30 ខែ វិច្ឆិកា ឆ្នាំ 2024
ម៉ោង លិខិតលេខ 6429

**កម្មវត្ថុ៖** សូមគោរពជូនសេចក្តីពន្យល់អំពីភាពដូចគ្នា និងខុសគ្នា នៃបារីអេឡិចត្រូនិក (Electronic Cigarette/ E-Cigarette) និងផលិតផល អេចឈ៍ ធី ភី (HTPs = Heated Tobacco Products)។

**យោង** ៖ ស្មារតីអង្គប្រជុំថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២៤ របស់គណៈកម្មាធិការអន្តរក្រសួង ស្តីពីសុខភាពសិក្សា។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន **ឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា ក្រសួងសុខាភិបាលបានរៀបចំសេចក្តីពន្យល់អំពីភាពដូចគ្នា និងខុសគ្នា នៃបារីអេឡិចត្រូនិក (Electronic Cigarette/E-Cigarette) និងផលិតផល អេចឈ៍ ធី ភី (HTPs= Heated Tobacco Products) ដែលរៀបចំឡើងដោយនាយកដ្ឋាននីតិកម្មនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល និងពិនិត្យកែសម្រួលដោយអង្គភាពជំនាញពីរ គឺនាយកដ្ឋានសុខភាពផ្លូវចិត្ត និងការបំពានគ្រឿងញៀន និងមជ្ឈមណ្ឌលជាតិលើកកម្ពស់សុខភាព ដែលមានខ្លឹមសារពន្យល់ដូចតទៅ៖

ក.ភាពដូចគ្នា

- សារធាតុនីកូទីន៖ ជាទូទៅបារីអេឡិចត្រូនិក និងផលិតផល អេចឈ៍ ធី ភី មានសារធាតុនីកូទីនដូចគ្នា
- ចំហាយ៖ បារីអេឡិចត្រូនិក និងផលិតផលអេចឈ៍ ធី ភី ប្រើប្រាស់ឧបករណ៍អេឡិចត្រូនិកសម្រាប់ជក់ ដែលដំណើរការដោយថ្មពិល សម្រាប់កម្តៅសូលុយស្យុងនីកូទីន ឬសរសៃថ្នាំជក់ ឱ្យក្លាយជាចំហាយ សម្រាប់អ្នកជក់ស្រូបចូល ដោយមិនបង្កើតឱ្យមានផ្សែងទេ។
- ភាពញៀននឹងនីកូទីន៖ ការជក់បារីអេឡិចត្រូនិក និងផលិតផល អេចឈ៍ ធី ភី បណ្តាលឱ្យមានការញៀននឹងនីកូទីន ដូចអ្នកញៀនបារីដែរ។
- ប៉ះពាល់ដល់ខួរក្បាល៖ ការស្រូបយកជាតិនីកូទីនបណ្តាលឱ្យប៉ះពាល់យ៉ាងខ្លាំងដល់ការលូតលាស់ខួរក្បាល ជាពិសេសកុមារនិងយុវវ័យ
- ប៉ះពាល់ដល់ប្រព័ន្ធដកដង្ហើម៖ ការស្រូបយកចំហាយអាចបង្ករបួស ឬរលាកសួតធ្ងន់ធ្ងរ



អាសយដ្ឋាន៖ ផ្លូវលេខ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទ៖(+៨៥៥) ២៣ ៨៨៥ ៩៧០
អ៊ីម៉ែល៖ info@moh.gov.kh
គេហទំព័រ៖ www.moh.gov.kh
តេឡេក្រាម៖ t.me/MOHCambodia

- បេះដូង និងសរសៃឈាម៖ ការស្រូបយកជាតិនីកូទីនអាចបង្កើនចង្វាក់បេះដូង បង្កើនសម្ពាធឈាម បង្កហានិភ័យដល់បេះដូងនិងសរសៃឈាម
- សារធាតុពុល៖ បារីអេឡិចត្រូនិក និងផលិតផល អេចឈ៍ ធី ភី មានសារធាតុដែលបណ្តាលឱ្យមានគ្រោះថ្នាក់ដល់សុខភាពជាច្រើន ទោះបីជាសារធាតុទាំងនោះមានប្រភេទខុសគ្នាក៏ដោយ។
  - ជំងឺមហារីក៖ សារធាតុ Carcinogen ដែលអាចបណ្តាលឱ្យមានជំងឺមហារីក
  - តម្រងនោម និងសរីរាង្គផ្សេងទៀត៖ មានសារធាតុលោហៈធ្ងន់ (Heavy metal) ដែលបណ្តាលឱ្យមានជំងឺតម្រងនោម និងសរីរាង្គផ្សេងទៀត។
- ប៉ះពាល់ដល់អ្នកក្បែរខាងដែលស្រូបយកចំហាយ៖ តិច ឬច្រើនអ្នកក្បែរខាងដែលស្រូបយកចំហាយពីអ្នកជក់បារីអេឡិចត្រូនិក និងផលិតផល អេចឈ៍ ធី ភី រងផលប៉ះពាល់ដល់សុខភាពផងដែរ។
- ឧបករណ៍៖ ឧបករណ៍អេឡិចត្រូនិកដែលប្រើប្រាស់សម្រាប់ជក់បារីអេឡិចត្រូនិក និងផលិតផល អេចឈ៍ ធី ភី ក៏អាចប្រើប្រាស់សម្រាប់ជក់គ្រឿងញៀនដទៃទៀតផងដែរ។
- បច្ចុប្បន្ន មានផលិតផល អេចឈ៍ ធី ភី កូនកាត់ (HTPs Hybrid) ដែលអាចដាក់បញ្ចូលសូលុយស្យុងផ្តល់សេជាតិនិងក្លិន ទៅក្នុងឧបករណ៍អេឡិចត្រូនិកសម្រាប់ជក់ ដូចបារីអេឡិចត្រូនិកដែរ។

ខ.ភាពខុសគ្នា

ចំនុចខុសគ្នាតែមួយរវាងបារីអេឡិចត្រូនិក និងផលិតផល អេចឈ៍ ធី ភី គឺប្រភេទនៃនីកូទីន ដោយបារីអេឡិចត្រូនិកប្រើប្រាស់សូលុយស្យុងនីកូទីនសំយោគ និងផលិតផល អេចឈ៍ ធី ភី ប្រើប្រាស់នីកូទីនធម្មជាតិចេញពីសរសៃថ្នាំជក់។

តារាងសង្ខេបភាពខុសគ្នា និងភាពដូចគ្នារវាងបារីអេឡិចត្រូនិក និងផលិតផល អេចឈ៍ ធី ភី

| | បារីអេឡិចត្រូនិក | ផលិតផល អេចឈ៍ ធី ភី |
|---|---|---|
| ភាពខុសគ្នា | - នីកូទីនជាសូលុយស្យុងសំយោគ<br>- ភាគច្រើនមានរសជាតិ/ក្លិន | - នីកូទីនជាសរសៃថ្នាំជក់<br>- ភាគច្រើនគ្មានរសជាតិ/ក្លិន |
| ភាពដូចគ្នា | - ប្រើប្រាស់ឧបករណ៍អេឡិចត្រូនិកសម្រាប់ជក់ ដែលដំណើរការដោយថ្មពិល សម្រាប់កម្ដៅ<br>- មានសារធាតុនីកូទីន<br>- បណ្តាលឱ្យញៀននឹងនីកូទីន<br>- ប៉ះពាល់ដល់ខួរក្បាល សួត បេះដូង និងសរសៃឈាម ជំងឺមហារីក តម្រងនោម និងសរីរាង្គផ្សេងទៀត<br>- ប៉ះពាល់ដល់សុខភាពអ្នកស្រូបយកចំហាយផងដែរ<br>- អាចប្រើប្រាស់សម្រាប់ជក់គ្រឿងញៀនដទៃទៀតផងដែរ។ | |

សន្និដ្ឋាន ៖ ដូចនេះបារីអេឡិចត្រូនិក និងផលិតផល អេចឈ៍ ធី ភី គួរតែត្រូវហាមឃាត់៖

- ជាផលិតផលដែលធ្វើឱ្យញៀនខ្លាំង និងបង្កផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សុខភាព ជាពិសេសការលូតលាស់ខួរក្បាលរបស់កុមារនិងយុវវ័យ។
- ជាផលិតផលដែលត្រូវបានគេរចនាឡើងសម្រាប់ទាក់ទាញកុមារនិងយុវវ័យ ដោយមានរូបរាង ពណ៌ និងទំហំ ច្រើនប្រភេទសម្រាប់ជ្រើសរើស ជារូបតុក្កតា និងរបស់ក្មេងលេង។ ចំណែកការប្រើប្រាស់ផលិតផលទាំងនេះ កំពុងរាតត្បាតខ្លាំងក្នុងចំណោមកុមារនិងយុវវ័យ នៅតាមគ្រឹះស្ថានអប់រំ។
- ជាច្រកផ្លូវទៅកាន់ការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ផ្សេងទៀត ព្រោះឧបករណ៍អេឡិចត្រូនិចសម្រាប់ជក់បារីអេឡិចត្រូនិក និងផលិតផល អេចឈ៍ ធី ភី អាចប្រើសម្រាប់ជក់គ្រឿងញៀនផ្សេងទៀតបាន។ ម្យ៉ាងវិញទៀត ក៏ជាច្រកផ្លូវដែលនាំឱ្យកុមារនិងយុវវ័យ ឈានទៅជក់បារីធម្មតាផងដែរ នៅពេលដែលគេមានភាពញៀននឹងនីកូទីន។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់។

សូម **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ។ ...៨

សាស្ត្រាចារ្យ **ឈាង រ៉ា**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កំណត់ហេតុ

## កិច្ចប្រជុំលើកទី៥របស់គណៈកម្មាធិការអន្តរក្រសួងស្តីពីសុខភាពសិក្សាដើម្បីពិនិត្យនិងឆ្លង សេចក្តីព្រាងអនុក្រឹត្យស្តីពីវិធានការហាមឃាត់ប្រើប្រាស់ ឧបករណ៍អេឡិចត្រូនិកសម្រាប់ជក់និងស៊ីសា

ថ្ងៃចន្ទ ១១រោច ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២៤ វេលាម៉ោង ៨:៣០នាទីព្រឹក នៅសណ្ឋាគារសាន់វេ រាជធានីភ្នំពេញ គណៈកម្មាធិការអន្តរក្រសួងស្តីពីសុខភាពសិក្សា ដែលហៅកាត់ថាគ.អ.ស.ស.បានរៀបចំកិច្ចប្រជុំលើកទី៥ ក្រោមអធិបតីភាពដឹកនាំដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ ជួន ណារ៉ុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងជាប្រធានគ.អ.ស.ស.។ កិច្ចប្រជុំនេះមានការចូលរួមពីឯកឧត្តម លោកជំទាវ មកពីក្រសួង ស្ថាប័នពាក់ព័ន្ធរួមមាន ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងសុខាភិបាល ក្រសួងធម្មការនិងសាសនា ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងការពារជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងពាណិជ្ជកម្ម ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រសួងផែនការ ក្រសួងព័ត៌មាន ក្រសួងយុត្តិធម៌ ក្រសួងអធិការកិច្ច ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងទេសចរណ៍ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងកិច្ចការនារី ក្រសួងមុខងារសាធារណៈដែលជាអនុប្រធាន សមាជិក សមាជិកានៃគ.អ.ស.ស. និងឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានីខេត្តទាំងអស់ សមាជិកនៃគ.អ.ស.ស. ព្រមទាំងឯកឧត្តម លោកជំទាវ លោក លោកស្រីតំណាងអញ្ជើញមកពីអគ្គស្នងការនគរបាលជាតិ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យានៃក្រសួងមហាផ្ទៃ ថ្នាក់ដឹកនាំនៃលេខាធិការដ្ឋានគ.អ.ស.ស. និងអង្គការចលនាដើម្បីសុខភាព កម្ពុជា ព្រមទាំងតំណាងដៃគូអភិវឌ្ឍន៍ ដែលមានវត្តមានសរុបចំនួន៩៣រូប ស្រី៣២រូប។

កិច្ចប្រជុំបានប្រព្រឹត្តទៅតាមរបៀបវារៈដូចខាងក្រោម៖

១- មតិស្វាគមន៍ ប្រកាសបើកកិច្ចប្រជុំ និងសង្ខេបលទ្ធផលចន្លោះកិច្ចប្រជុំគណៈកម្មាធិការអន្តរក្រសួងស្តីពីសុខភាពសិក្សា កន្លងមកដល់បច្ចុប្បន្ន ដោយឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ ជួន ណារ៉ុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងជាប្រធានគណៈកម្មាធិការអន្តរក្រសួងស្តីពីសុខភាពសិក្សា (គ.អ.ស.ស.)។

២- ការបង្ហាញសារបានៃការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីវិធានការហាមឃាត់ ការនាំចូល ការផលិត ការចែកចាយ ការលក់ ការផ្សាយពាណិជ្ជកម្ម ការប្រើប្រាស់ និងការកាន់កាប់ ឧបករណ៍និងសារធាតុអេឡិចត្រូនិកសម្រាប់ជក់ និងស៊ីហ្សា ដោយ ឯកឧត្តមសាស្ត្រាចារ្យ **ឃីត ស៊ុនណារ៉ា** រដ្ឋលេខាធិការក្រសួង សុខាភិបាល និងជាអនុប្រធានគណៈកម្មាធិការអន្តរក្រសួងស្តីពីសុខភាពសិក្សា(គ.អ.ស.ស.)។

៣- ការពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីវិធានការហាមឃាត់ ការនាំចូល ការផលិត ការចែកចាយ

ការលក់ ការផ្សាយពាណិជ្ជកម្ម ការប្រើប្រាស់ និងការកាន់កាប់ ឧបករណ៍និងសារធាតុអេឡិចត្រូនិកសម្រាប់ជក់ និងស៊ីស្សា។

ជាកិច្ចចាប់ផ្តើម ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ ជួន ណារ៉ុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងជាប្រធានគណៈកម្មាធិការអន្តរក្រសួងស្តីពីសុខភាពសិក្សា(គ.អ.ស.ស.) បានមានប្រសាសន៍ថ្លែងអំណរគុណចំពោះការចូលរួមរបស់ឯកឧត្តម លោកជំទាវ អនុប្រធាន សមាជិក សមាជិកនៃគ.អ.ស.ស.និងប្រតិភូអមដំណើរ ព្រមទាំងដៃក្រសួង ស្ថាប័ន អង្គភាព និងដៃគូអភិវឌ្ឍពាក់ព័ន្ធដែលបានអញ្ជើញចូលរួមកិច្ចប្រជុំដ៏មានសារសំខាន់ក្នុងថ្ងៃនេះ។ បន្ទាប់ពីបានពិភាក្សាលើរបាយការណ៍ស្តីពីការប្រើប្រាស់នូវឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់និងស៊ីស្សា ដែលបានពិភាក្សាគ្នាកាលពីកិច្ចប្រជុំលើកមុន ហើយក៏បានឯកភាពគ្នានិងសម្រេចថាស្នើសុំក្រសួងសុខាភិបាលរៀបចំសេចក្តីព្រាងអនុក្រឹត្យមួយដើម្បីដាក់ជូន ត្រួតពិនិត្យនិងស្នើទៅរាជរដ្ឋាភិបាលធ្វើការពិចារណានិងសម្រេច។ ទន្ទឹមនោះ ឯកឧត្តមបណ្ឌិតសភាចារ្យប្រធានអង្គប្រជុំ បានថ្លែងអំណរគុណដល់ឯកឧត្តមសាស្ត្រាចារ្យ **យឹត ស៊ុនណារ៉ា** រដ្ឋលេខាធិការក្រសួងសុខាភិបាល និងជា អនុប្រធានគណៈកម្មាធិការអន្តរក្រសួងស្តីពីសុខភាពសិក្សា (គ.អ.ស.ស.) ដែលបានដឹកនាំការរៀបចំនូវសេចក្តីព្រាងអនុក្រឹត្យនេះឡើង ព្រមទាំងបានប្រកាសបើកកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីវិធានការហាមឃាត់ ការនាំចូល ការផលិត ការចែកចាយ ការលក់ ការផ្សាយពាណិជ្ជកម្ម ការប្រើប្រាស់ និងការកាន់កាប់ឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមី សម្រាប់ជក់ ហ៊ីត និងស៊ីស្សា។

ជាកិច្ចបន្ត ឯកឧត្តមសាស្ត្រាចារ្យ **យឹត ស៊ុនណារ៉ា** រដ្ឋលេខាធិការក្រសួងសុខាភិបាល និងជាអនុប្រធានគណៈកម្មាធិការអន្តរក្រសួងស្តីពីសុខភាពសិក្សា (គ.អ.ស.ស.) បានបង្ហាញពីសារបេធនៃការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីវិធានការហាមឃាត់ ការនាំចូល ការផលិត ការចែកចាយ ការលក់ ការផ្សាយពាណិជ្ជកម្ម ការប្រើប្រាស់ និងការកាន់កាប់ ឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ ហ៊ីត និងស៊ីស្សា ដោយបានគូសបញ្ជាក់ថា ឆ្លងតាមការសម្រេចនៃកិច្ចប្រជុំពិភាក្សាស្វែងរកវិធានការ ហាមឃាត់ លើការប្រើប្រាស់ និងចែកចាយបារីអេឡិចត្រូនិកនិង ស៊ីស្សាក្នុងចំណោមយុវជនដែលកិច្ចប្រជុំបានប្រព្រឹត្តទៅកាលពីថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៤ ក្រោមការដឹកនាំដ៏ខ្ពស់ដោយ ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**។ លទ្ធផលនៃអង្គប្រជុំនេះបានបង្ហាញឱ្យឃើញថាបារីអេឡិចត្រូនិកជាផលិតផលដ៏មានគ្រោះថ្នាក់បំផុត ដោយសារមានការផ្ទុកនូវជាតិនីកូទីន និងសារជាតិគីមី ផ្សេងៗទៀតដែលធ្វើឱ្យអ្នកប្រើប្រាស់ញៀនខ្លាំង ជាពិសេសចំពោះយុវជននិងកុមារ និងប៉ះពាល់ដល់ខួរក្បាលបណ្តាលឱ្យមានវិបត្តិក្នុងការចងចាំមិនបានល្អ និងវិបត្តិក្នុងការផ្តង់អារម្មណ៍ក្នុងការបំពេញការងារ ពិសេសក្នុងការសិក្សា ថែមទាំងធ្វើឱ្យប៉ះពាល់សួត របួសសួត ប៉ះពាល់ដល់បេះដូង និងតម្រងនោម។ យោងតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ ជួន ណារ៉ុន** ដែលបានកំណត់ចង្អុលកាលពីអង្គប្រជុំថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៤ បានចង្អុលនូវលទ្ធភាពក្នុងការបង្កើតឱ្យមានអនុក្រឹត្យ ដើម្បីគ្រប់គ្រងការផលិត ការប្រើប្រាស់បារីអេឡិចត្រូនិកនេះ។ អង្គប្រជុំពេលនោះក៏បានសម្រេចឱ្យមានការរៀបចំបង្កើតអនុក្រឹត្យមួយចាំបាច់ជាបន្ទាន់ក្នុងការគ្រប់គ្រង និងហាមឃាត់ការប្រើប្រាស់ ការចែកចាយឧបករណ៍អេឡិចត្រូនិកសម្រាប់ជក់ ហ៊ីត និងស៊ីស្សាឱ្យមានប្រសិទ្ធភាព ដើម្បីការពារសុខភាពអ្នកអប់រំ អ្នកសិក្សា និងសុខភាពសាធារណៈ។ ដោយបច្ចុប្បន្នបានសង្កេតឃើញថាមានការកើនឡើងនៃការប្រើប្រាស់ឧបករណ៍អេឡិចត្រូនិកនិងថ្នាំជក់ដែលផ្ទុកដោយសារជាតិនីកូទីននិងមានការពេញនិយមក្នុងចំណោមយុវវ័យតាមសាលារៀន អង្គប្រជុំបានសម្រេចប្រគល់ជូនក្រសួងសុខាភិបាល

រៀបចំសេចក្តីព្រាងអនុក្រឹត្យនេះ។ បន្ទាប់ពីកិច្ចប្រជុំអន្តរក្រសួងមក ឯកឧត្តមសាស្ត្រាចារ្យ បានធ្វើរបាយការណ៍ស្តីពីលទ្ធផលអង្គប្រជុំជូន ឯកឧត្តមសាស្ត្រាចារ្យ **ឈៀង រ៉ា** រដ្ឋមន្ត្រីក្រសួងសុខាភិបាល បន្ទាប់មកឯកឧត្តមក៏បានឯកភាព និងចាត់តាំងឱ្យនាយកដ្ឋាននីតិកម្មនៃក្រសួងសុខាភិបាលបង្កើតជាក្រុមការងារបច្ចេកទេស រៀបចំនូវសេចក្តីព្រាងអនុក្រឹត្យនេះ។ ក្រុមការងារបច្ចេកទេសនៃក្រសួងសុខាភិបាលក៏បានរៀបចំតាក់តែងសេចក្តីព្រាងអនុក្រឹត្យនេះឡើងដោយខ្លឹមសារនៃសេចក្តីព្រាងនេះបានផ្អែកលើសេចក្តីណែនាំនិងសេចក្តីជូនដំណឹងផ្សេងៗដែលក្រសួង និងស្ថាប័នមួយចំនួនធ្លាប់បានដាក់ចេញកន្លងមក ដូចជា អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងទេសចរណ៍។ល។ រីឯផ្នែកបច្ចេកទេសនៃសេចក្តីព្រាងអនុក្រឹត្យនេះ ក៏បានយោងឯកសាររបស់អង្គការសុខភាពពិភពលោកនិងស្ថាប័នសុខភាពផ្សេងទៀតផងដែរ។ នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៤ នាយកដ្ឋាននីតិកម្មនៃក្រសួងសុខាភិបាលបានរៀបចំកិច្ចប្រជុំដើម្បីពិនិត្យនិងពិភាក្សាជាមួយអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសុខាភិបាលលើខ្លឹមសារនៃសេចក្តីព្រាងអនុក្រឹត្យនេះ។ កិច្ចប្រជុំបានផ្តល់យោបល់កែសម្រួល និងបានឯកភាពនូវខ្លឹមសារនៃសេចក្តីព្រាងអនុក្រឹត្យនេះដែលមាន៥ជំពូក១៩មាត្រា។ ក្នុងនោះ ជំពូកទី១ ចែងអំពីបទប្បញ្ញត្តិ ទូទៅដែលមាន៣មាត្រា ជំពូកទី២ ចែងអំពីស្ថាប័នមានសមត្ថកិច្ចដែលមាន៨មាត្រា ជំពូកទី៣ ចែងអំពីការហាមឃាត់ដែលមាន៤មាត្រា ជំពូកទី៤ចែងអំពីទណ្ឌកម្មដែលមាន២មាត្រា និងជំពូកទី៥ ចែងអំពីអវសានប្បញ្ញត្តិដែលមាន ២មាត្រា។ បន្ទាប់ពីបានសម្រេចនូវសេចក្តីព្រាងអនុក្រឹត្យនេះ ក្រសួងសុខាភិបាលក៏បានសរសេរលិខិតលេខ០០២៣សនក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៤ ដើម្បីស្នើសុំឆ្លងឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ ជួន ណារ៉ុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងជាប្រធានគណៈកម្មាធិការអន្តរក្រសួង ស្តីពីសុខភាពសិក្សា ពិនិត្យនិងដាក់ជូនអង្គប្រជុំតាមការគួរ។

បន្ទាប់ពីការបង្ហាញស្តីពីសារបាននៃការរៀបចំសេចក្តីព្រាងអនុក្រឹត្យដោយ ឯកឧត្តមសាស្ត្រាចារ្យ **យឹម ស៊ិន ណារ៉ា** រួចមក អង្គប្រជុំបានធ្វើការពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីវិធានការហាមឃាត់ ការនាំចូល ការផលិត ការចែកចាយ ការលក់ ការផ្សាយពាណិជ្ជកម្ម ការប្រើប្រាស់ និងការកាន់កាប់ ឧបករណ៍និងសារធាតុអេឡិចត្រូនិកសម្រាប់ជក់ ហឺត និងស៊ីហ្សា ដែលមានការចូលរួមផ្តល់មតិយោបល់ដូចខាងក្រោម៖

១. ឯកឧត្តម **សោម រតនា** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី បានមានប្រសាសន៍ចូលរួមក្នុងការកែលម្អចំណងជើងនៃសេចក្តីព្រាងអនុក្រឹត្យដោយសូមឱ្យកែសម្រួលឃ្លាឧបករណ៍និងសារធាតុអេឡិចត្រូនិកមកជា ឧបករណ៍អេឡិចត្រូនិកនិង សារធាតុគីមី ព្រមទាំងស្នើឱ្យប្តូរពាក្យ ស៊ីហ្សា មកជា ស៊ីស្សា វិញ។

**ឯកឧត្តមបណ្ឌិតសភាចារ្យប្រធានអង្គប្រជុំ** បានឯកភាពក្នុងការកែសម្រួលឃ្លា ឧបករណ៍និងសារធាតុអេឡិចត្រូនិកមកជា ឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមី ព្រមទាំងផ្លាស់ប្តូរពាក្យ ស៊ីហ្សា មកជា ស៊ីស្សា។

២. ឯកឧត្តម **កែវ គី រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ និងនវានុវត្តន៍** បានស្នើឱ្យលើកពាក្យ ការ ផលិត មកដាក់ជាប់ពាក្យឧបករណ៍អេឡិចត្រូនិកដើម្បីឱ្យការ នាំចូល ការចែកចាយ វានៅបន្តជាប់គ្នាហូរហែ។ ចំពោះមាត្រា៧ ឯកឧត្តមសូមឱ្យលុបពាក្យ "ហាមឃាត់ការផលិត" ព្រោះពាក្យនេះប្រើក្នុងសមត្ថកិច្ចក្រសួងពាណិជ្ជកម្ម។ មួយវិញទៀត ឯកឧត្តមស្នើឱ្យអង្គប្រជុំពិចារណាលើការប្រើពាក្យ "ការផលិត" ព្រោះនិយមន័យក្នុងនេះមើលទៅមិនមានការបញ្ជាក់ថា ការផលិតនេះគឺសំដៅតែការផលិត និងចែកចាយក្នុងស្រុក ឬមួយរួមទាំងការផលិតនាំចេញដែរ ដោយសារកន្លងមកដូចជាមានព័ត៌មានថា នៅខេត្តព្រះសីហនុមានការអនុញ្ញាតឱ្យបើករោងចក្រមួយកាល

ពីឆ្នាំ២០១៩ ដូច្នេះបើសិនវាប្រើសម្រាប់តែ ហាមឃាត់ការផលិតលក់ ចែកចាយក្នុងស្រុកទេ សូមស្នើទៅអង្គប្រជុំបញ្ជាក់ឱ្យច្បាស់ ព្រោះថា បើយើងក្តោបទាំងការផលិតនាំចេញ វាអាចខ្វាស់ជាមួយគម្រោងវិនិយោគដែលបានអនុញ្ញាតទៅក្រុមហ៊ុនណាមួយរួចមកហើយ។

**ឯកឧត្តមបណ្ឌិតសភាចារ្យប្រធានអង្គប្រជុំ** បានឯកភាពយកពាក្យការផលិត មកដាក់ជាប់នឹងពាក្យ ការកាន់កាប់ (វិធានការហាមឃាត់ការនាំចូល ការចែកចាយ ការលក់ ការផ្សាយពាណិជ្ជកម្ម ការប្រើប្រាស់ ការកាន់កាប់ និងការផលិតឧបករណ៍អេឡិកត្រូនិកនិងសារធាតុគីមីសម្រាប់ជក់និងស៊ីស្សា)។ ពាក់ព័ន្ធនឹងការផលិតក្នុងស្រុកឬ ក៏នាំចេញ បើសិនយើងដាក់ថា យើងអនុញ្ញាតឱ្យផលិតនាំចេញ ប៉ុន្តែមិនអនុញ្ញាតឱ្យប្រើប្រាស់ក្នុងស្រុកទេ ក៏យើងអាចបង្កកបានដែរ នេះជាការស្នើសុំចំពោះការពិនិត្យនិងសម្រេចពីរាជរដ្ឋាភិបាល។ ចំពោះការសម្រេចយ៉ាងណាៗអាស្រ័យលើរាជរដ្ឋាភិបាលពិនិត្យនិងថ្លឹងថ្លែង។ ពាក់ព័ន្ធជាមួយរោងចក្រដែលអនុម័តរួចហើយគឺអត់ថយទេ។ ជារួមច្បាប់នៅពេលអនុម័តគឺគេមិនថយក្រោយទេ ប៉ុន្តែនេះ គឺជាការបង្ហាញពីឆន្ទៈរបស់រដ្ឋាភិបាលក្នុងការការពារទេ បើយើងថាហាមឃាត់ក្នុងស្រុក ហើយអនុញ្ញាតឱ្យផលិតនាំចេញ វាជាបញ្ហាដែលពាក់ព័ន្ធនឹងផ្លូវច្បាប់ ហើយក៏មិនអាចត្រួតពិនិត្យបានដែរ។ ជារួមខ្ញុំជឿជាក់ថាបើពាក់ព័ន្ធជាមួយសារធាតុផ្សំ ទាំងសារធាតុគីមី ទាំងឧបករណ៍ ដូចជាស៊ីស្សា ថ្នាំជក់ និងវេបមិនមានសារធាតុដើមណាដើម្បីអាចផលិតក្នុងស្រុកបានទេ។ ប្រសិនបើគេស្នើសុំនោះគ្រាន់តែជាការនាំចូលទាំងស្រុង និងគ្រាន់តែមកប្រមូលផ្តុំដើម្បីនាំចេញឬមួយចែកចាយផ្ទៃក្នុងដោយគេចការបង់ពន្ធទេ។ បើពាក់ព័ន្ធជាមួយសារធាតុគីមី និងឧបករណ៍ គឺត្រូវនាំចូលទាំងអស់ ដូច្នេះមិនអាចថាក្រុមហ៊ុនមកផលិតក្នុងស្រុកទេ គឺគ្រាន់តែផ្តុំអីនោះអាចថាបាន។ ដូចនេះ ចំពោះថាតើជាគោលការណ៍យ៉ាងណា សូមសម្រេចថាទុកជូនរាជរដ្ឋាភិបាលសម្រេចចុះ។

៣. ឯកឧត្តម **ឡៅ ហ៊ីម** រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានស្នើសុំឱ្យលែងសុខភាពកម្មករនិយោជិក នៅត្រង់ជំពូក១ មាត្រា១ ព្រោះថា អនុក្រឹត្យនេះ មានគោលបំណងការពារសុខភាពសាធារណៈ សុខភាពអ្នកសិក្សា បុគ្គលិកអប់រំ និងកម្មករនិយោជិត ដោយកំណត់អំពីវិធានការ យន្តការ បែបបទ និងនីតិវិធីក្នុងការគ្រប់គ្រង ជាពិសេសការហាមឃាត់ ការនាំចូល ការចែកចាយ ការលក់ ការផ្សាយពាណិជ្ជកម្ម ការប្រើប្រាស់ ការកាន់កាប់ការផលិត និងការស្តុកទុកឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ បឺត ហឺត ស្រូប និងស៊ីស្សា។

**ឯកឧត្តមបណ្ឌិតសភាចារ្យប្រធានអង្គប្រជុំ** សូមឱ្យកែសម្រួលតាមសំណូមពរ ដោយអនុញ្ញាតឱ្យលែងពាក់សុខភាពកម្មករ និយោជិក ក្នុងជំពូក១ ត្រង់មាត្រា១។

៤. ឯកឧត្តម **មាស វីរិទ្ធ** អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានសំណូមពរឱ្យកែសម្រួលមាត្រា២ត្រង់ឃ្លា អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះការនាំចូល ការផលិត ការចែកចាយ ការលក់... ទៅជា អនុក្រឹត្យនេះមានវិសាលភាពអនុវត្តទៅលើការនាំចូល ការផលិត ការចែកចាយ ការលក់...។ ឯកឧត្តមក៏បានលើកឡើងបន្ថែមទៀតថា ចំពោះមាត្រា៣ ចំណុចទី២ ទាក់ទងទៅនឹងបារីអេឡិចត្រូនិកនិងអេចឈ៍ ធី ក៏ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានស្នើគោលការណ៍ពីសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ដើម្បីដាក់ចេញនូវសារាចរណែនាំស្តីពីការទប់ស្កាត់ក្នុងឆ្នាំ២០១៤ ហើយទោះបីជាយើងមានសេចក្តីណែនាំក៏ពិតមែនតែមនុស្សនៅតែប្រព្រឹត្ត ដដែល។

៥. ឯកឧត្តម ហុក ឡៀង ប្រធាននាយកដ្ឋាននីតិកម្មនៃក្រសួងសុខាភិបាល មានប្រសាសន៍ថា ត្រង់មាត្រា៤ និងមាត្រា១០ ខ្លឹមសារដែលបានចែងរៀងស្រាសជាងមាត្រា៥ និងមាត្រា៩ ព្រោះសង្កេតឃើញថា ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងផ្សេងៗទៀត សុទ្ធតែបានប្រើពាក្យថា ចាត់វិធានការ។ ដោយឡែក ក្រសួងសុខាភិបាល និងក្រសួងសាធារណការនិងដឹកជញ្ជូនគ្រាន់តែប្រើពាក្យថា មានភារកិច្ច។

ឯកឧត្តមបណ្ឌិតសភាចារ្យប្រធានអង្គប្រជុំ បានអនុញ្ញាតឱ្យពិនិត្យកែសម្រួលត្រង់មាត្រា៤ ដែលកំណត់ភារកិច្ចជូនក្រសួងសុខាភិបាល ដោយសូមឱ្យដាក់ថា ក្រសួងសុខាភិបាល ត្រូវចាត់វិធានការចេញសេចក្តីណែនាំនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងអប់រំផ្សព្វផ្សាយអំពីផលប៉ះពាល់សុខភាពនិងគ្រោះថ្នាក់នៃការប្រើប្រាស់ឧបករណ៍អេឡិកត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ បឺត ហឺត ស្រូប និងស៊ីស្សា។ ចំណែកឯមាត្រា១០ ក្រសួងសាធារណការ និងដឹកជញ្ជូន សូមដាក់ថា ក្រសួងសាធារណការនិងដឹកជញ្ជូន ត្រូវចាត់វិធានការចេញសេចក្តីណែនាំនិងលិខិតបទដ្ឋានគតិយុត្ត ស្តីពីការហាមឃាត់ការដឹកជញ្ជូន ឧបករណ៍អេឡិកត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ បឺត ហឺត ស្រូប និងស៊ីស្សា ដល់គ្រប់អង្គភាពសាធារណៈនិងឯកជនដែលពាក់ព័ន្ធនឹងវិស័យដឹកជញ្ជូន។ ឯកឧត្តមក៏បានមានប្រសាសន៍ឱ្យបន្ថែមមាត្រាថ្មីមួយទៀត គឺក្រសួងការងារនិងបណ្តុះបណ្តាល វិជ្ជាជីវៈ។

៦. លោកជំទាវ ម៉ែន សុមនា រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានលើកជាសំណូមពរឱ្យលុបមាត្រា៦ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចេញ ដោយគ្រាន់តែបូកបញ្ចូលជាមួយក្រសួងស្ថាប័នណាដែលមានច្បាប់ និងអនុក្រឹត្យសម្រាប់អនុវត្តនិងបានរៀបចំរួច។ លោកជំទាវបានមានប្រសាសន៍បន្ថែមទៀតថា ចំពោះការនាំចូល បើមានច្បាប់ហាមឃាត់ហើយ ក្រសួងសេដ្ឋកិច្ចមិនអនុញ្ញាតទេ។ ដូច្នេះគ្រាន់តែដាក់វិលេចត្រូវតែអនុវត្តទៅតាមច្បាប់ជាធរមាន ដោយបូកបញ្ចូលជាមួយនឹងក្រសួង ស្ថាប័នណាមួយ គឺអាចគ្រប់គ្រងទៅដល់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុហើយ។

៧. ឯកឧត្តម ពឹម សន្ធា តំណាងក្រសួងពាណិជ្ជកម្ម បានលើកឡើងថា ចំពោះមាត្រា៧ គឺមានភាពទូលំទូលាយដែលពាក់ព័ន្ធនឹងច្បាប់និងអនុក្រឹត្យជាច្រើន ឧទាហរណ៍ដូចជា ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ និងច្បាប់ស្តីពី E-Commerce ជាដើម ដោយយើងអាចប្រើជាឧបសម្ព័ន្ធមួយដែលយោងទៅតាមច្បាប់ដែលមានស្រាប់ ពីព្រោះនៅក្នុងក្រសួងនីមួយៗតែងតែមានច្បាប់អមទៅជាមួយ ដូច្នេះនៅពេលច្បាប់ចេញជាធរមាន មានន័យថា ក្រសួងនីមួយៗបានដឹងថាដែនកំណត់សមត្ថកិច្ចធ្វើអីនៅក្នុងមាត្រាណាមួយបាន។

ឯកឧត្តមបណ្ឌិតសភាចារ្យប្រធានអង្គប្រជុំ មានប្រសាសន៍ថា មាត្រា៧សូមកែសម្រួលដោយលុបពាក្យ ការផលិតចេញ និងបន្ថែមពាក្យថា ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមានវិញ ថា ក្រសួងពាណិជ្ជកម្ម ត្រូវចាត់វិធានការចេញសេចក្តីណែនាំនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីហាមឃាត់ការចែកចាយ ការលក់ និងការស្តុកទុកឧបករណ៍អេឡិកត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ បឺត ហឺត ស្រូប និងស៊ីស្សា ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

៨. ឯកឧត្តម ឆូ នា អភិបាលរងនៃគណៈអភិបាលខេត្តបាត់ដំបង បានមានមតិចូលរួមសូមកែសម្រួលមាត្រា៩ ដែលចែងពីបទល្មើសនៃការផ្សព្វផ្សាយ។ ឯកឧត្តមលើកឡើងថា កាលណាមានបទល្មើសហើយ មិនមែនតាមដានស្វែងរកទេ គឺមានតែទប់ស្កាត់ និង បង្ក្រាប។ ដូចនេះ ឯកឧត្តមសូមឱ្យកែសម្រួលពីពាក្យ តាមដានស្វែងរកមកជា ទប់ស្កាត់និងបង្ក្រាបវិញ។

៩. ឯកឧត្តម **ហ៊ុក ខៀវ** ប្រធាននាយកដ្ឋាននីតិកម្មនៃក្រសួងសុខាភិបាល បានស្នើសុំឱ្យលុបពាក្យអប់រំផ្សព្វផ្សាយនៅមាត្រា៤ ព្រោះថា ក្រសួងសុខាភិបាល មានផែនការសកម្មភាពចុះទៅអប់រំផ្សព្វផ្សាយដល់សហគមន៍តែម្តង រីឯក្រសួងអប់រំ យុវន និងកីឡាក៏មានភារកិច្ចដូចគ្នា។ ហេតុនេះនៅក្នុងមាត្រា៤ ដែលចែងថាក្រសួងសុខាភិបាលត្រូវចាត់វិធានការចេញសេចក្តីណែនាំនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធប៉ុណ្ណឹងល្អហើយ ។

**ឯកឧត្តមបណ្ឌិតសភាចារ្យប្រធានអង្គប្រជុំ** បានលើកឡើងថា ចំពោះភារកិច្ចអប់រំផ្សព្វផ្សាយ គឺជាសេវាពាក់ព័ន្ធការងារបច្ចេកទេស និងពាក់ព័ន្ធនឹងរបាយការណ៍អង្គការដៃគូ ពិសេសអង្គការ WHO ជាទម្រង់បែបវិទ្យាសាស្ត្រ ដូច្នេះការអប់រំផ្សព្វផ្សាយរបស់សុខាភិបាលខុសពីក្រសួងអប់រំ យុវជន និងកីឡា។ ការអប់រំផ្សព្វផ្សាយរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺគ្រាន់តែអប់រំមិនឱ្យប្រើប្រាស់ និងហាមឃាត់ទេ ចំណែកសុខាភិបាលត្រូវតែមានទឡ្ហីករណ៍វិទ្យាសាស្ត្រច្បាស់លាស់។

១០. ឯកឧត្តម **សុខ ពិសី អភិបាលរងនៃគណៈអភិបាលខេត្តប៉ៃលិន** មានប្រសាសន៍លើកឡើងថាការរៀបចំឃ្លានិងខ្លឹមសារ ឃើញថាមានចំណុចច្រើន តែហាក់ដូចជាមិនឃើញបង្ហាញពីការហាមឃាត់ការចេញអាជ្ញាបណ្ណ ដូច្នេះលោកសូមឱ្យហាមឃាត់ការចេញអាជ្ញាបណ្ណផងដែរ។ បន្ទាប់មក លោកបានលើកឡើងបន្ថែមទៀតថាមានក្រសួងមួយដែលមាតួនាទីសំខាន់គឺក្រសួងទេសចរណ៍ ដែលដូចជាមិនមានចែងពីតួនាទីភារកិច្ចរបស់ក្រសួងនេះ។ ដោយសារ កន្លែងខ្លះមានការលាក់ខ្លួនប្រើប្រាស់និងការចែកចាយនៅតាមតំបន់ទេសចរណ៍ ដែលគួរពិចារណាពីតួនាទីរបស់ក្រសួងនេះ នៅក្នុងសេចក្តីព្រាងអនុក្រឹត្យនេះ។ មួយទៀត តើយើងបានពិចារណាលើវិសាលភាពនិងគោលដៅហាមឃាត់ជាមួយភ្ញៀវអន្តរជាតិដែលគាត់មកលេងស្រុកយើងដែរឬទេ? ករណីគាត់នាំឧបករណ៍ហ្នឹងមកដែរតើយើងហាមឃាត់គាត់បែបណា? ហើយតើវិសាលភាពនេះយើងប្រើកម្រិតណា ត្រូវហាមឃាត់ជាលក្ខណៈជាតិឬបែបណា?

**ឯកឧត្តមបណ្ឌិតសភាចារ្យប្រធានអង្គប្រជុំ** បានមានប្រសាសន៍ថាពាក់ព័ន្ធជាមួយសណ្ឋាគារគឺស្ថិតនៅក្នុងក្របខណ្ឌរដ្ឋបាលថ្នាក់ក្រោមជាតិ ហេតុនេះហើយបានជាយើងមិនដាក់ក្រសួងទេសចរណ៍ នៅពេលអនុវត្តជាក់ស្តែងគឺរដ្ឋបាលថ្នាក់ក្រោមជាតិជាអ្នកអនុវត្ត។ ចំពោះជនបរទេសក៏យើងហាមឃាត់ដូចគ្នា មិនមែនថាជនបរទេសជក់បាន ហើយខ្មែរជក់អត់បាននោះទេ។ ចំពោះរឿងនេះយើងទុកជូនរាជរដ្ឋាភិបាលពិចារណា ថ្លឹងថ្លែង

និងសម្រេច ដោយយើងគ្រាន់តែប្រមើមើលតែប៉ុណ្ណោះ។

១១. ឯកឧត្តម **សោម រតនា** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី បានលើកឡើងថាគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់មានតួនាទីភារកិច្ចបង្ការនិងទប់ស្កាត់ ដោយឡែកមិនមានតួនាទីភារកិច្ចរបស់ក្រសួងធម្មការនិងសាសនា ព្រោះថា ក្រសួងធម្មការនិងសាសនានាពេលបច្ចុប្បន្ននេះមានព្រះសង្ឃជាង៧ម៉ឺនអង្គ ហើយព្រះសង្ឃនៅជាប់ផ្ទាល់ជាមួយប្រជាពលរដ្ឋច្រើន។ ដូច្នេះឯកឧត្តមបានស្នើសុំអង្គប្រជុំមេត្តាពិចារណាផង ចំពោះភារកិច្ចតាមវត្តអារាម និងនិកាយផ្សេងៗពាក់ព័ន្ធការអប់រំផ្សព្វផ្សាយ និងបង្ការ ទប់ស្កាត់។

**ឯកឧត្តមបណ្ឌិតសភាចារ្យប្រធានអង្គប្រជុំ** មានប្រសាសន៍តបថា នៅក្នុងមាត្រា១០យើងដាក់ក្រសួងស្ថាប័នពាក់ព័ន្ធ នៅក្នុងនោះរួមទាំងក្រសួងធម្មការនិងសាសនាផងដែរ។ បើយើងដាក់ថាព្រះសង្ឃនៅក្នុងនេះដែរវាចេះតែបានហើយ ប៉ុន្តែនៅក្នុងលិខិតបទដ្ឋានរបស់ក្រសួងនីមួយៗមានលម្អិតបន្ថែមទៀតរបស់ក្រសួងផ្សេងៗ ដូច្នេះ

ហើយយើងដាក់ថាក្រសួងស្ថាប័នពាក់ព័ន្ធត្រូវចូលរួមសហការអនុវត្តអប់រំផ្សព្វផ្សាយ និងបង្ការ ទប់ស្កាត់។

**១២.** ឯកឧត្តម **ខា អ៊ាន់ចាន់ អភិបាលនៃគណៈអភិបាលខេត្តវងកំពង់ធំ** បានទទូចស្នើសុំឱ្យមានតួនាទីភារកិច្ចរបស់ក្រសួងទេសចរណ៍នៅក្នុងអនុក្រឹត្យនេះ ដោយឯកឧត្តមលើកឡើងថា សណ្ឋាគារគឺនៅក្រោមរដ្ឋបាលថ្នាក់ក្រោមជាតិ ប៉ុន្តែវានៅមានកម្រិត។ សណ្ឋាគារ ភោជនីយដ្ឋាន និងតំបន់ទេសចរណ៍ខ្លះត្រូវផ្អែកតាមចំនួនចាប់ពីប៉ុន្មានទៅប៉ុន្មានគឺនៅក្រោមថ្នាក់ក្រសួងទេសចរណ៍។ មួយវិញទៀត ក្រសួងទេសចរណ៍ជាអ្នកដកហូតជាអ្នកផ្តល់អាជ្ញាបណ្ណជីវកម្ម។ យើងក៏បានឃើញនិងដឹងហើយថាក្មេងៗប្រើប្រាស់វេប នៅតាមសណ្ឋាគារ ភោជនីយដ្ឋាន ក្លឹប មជ្ឈមណ្ឌលកម្សាន្ត ហើយរឿងដែលម្ចាស់ក្លឹប ភោជនីយដ្ឋាន សណ្ឋាគារ គាត់ខ្លាចគឺអ្នកផ្តល់អាជ្ញាបណ្ណ ដូចនេះគួរតែដាក់សមត្ថកិច្ចរបស់ក្រសួងទេសចរណ៍។

**១៣.** លោកជំទាវ **ខណ្ណា សេរីរ័ត្ន អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍** បានលើកឡើងថា ក្រសួងទេសចរណ៍ជាក្រសួងចុងក្រោយមួយក្នុងការផ្តល់អាជ្ញាបណ្ណ។ បានន័យថាក្នុងការផ្តល់អាជ្ញាបណ្ណជូនភោជនីយដ្ឋាន សណ្ឋាគារ មណ្ឌលកម្សាន្តគឺក្រសួងទេសចរណ៍ផ្តល់អាជ្ញាបណ្ណចុងក្រោយបង្អស់ មានន័យថាគាត់ត្រូវមានឯកសារពាក់ព័ន្ធពីអាជ្ញាធរមូលដ្ឋាន និងក្រសួងនានាជាមុនសិន ដូចជា ឯកសារចុះអាជ្ញាបណ្ណពីក្រសួងពាណិជ្ជកម្មរួចពល់ជាមុនសិន ទើបមកក្រសួងទេសចរណ៍អាចផ្តល់អាជ្ញាបណ្ណតាមក្រោយ។ លោកជំទាវ បានលើកឡើងថាក្រសួងទេសចរណ៍បានផ្តល់សិទ្ធិអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដូច្នេះក្រសួងទេសចរណ៍បានផ្តល់អាជ្ញាបណ្ណខេដីរីចំនួនពីរតែប៉ុណ្ណោះក្រៅពីនេះ ក្រសួងបានផ្តល់សិទ្ធិអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការចេញអាជ្ញាបណ្ណវង្គសាល មណ្ឌលកម្សាន្តសម្រាប់មនុស្សពេញវ័យ។ មួយវិញទៀតលោកជំទាវឯកភាពជាមួយប្រធានអង្គប្រជុំចំពោះការដាក់ក្រសួងទេសចរណ៍មួយមាត្រាទៀតក៏បានឬក៏ដាក់ថាក្រសួងពាក់ព័ន្ធក៏បាន ក្រសួងទេសចរណ៍នឹងចូលរួមអនុវត្តឱ្យអស់ពីលទ្ធភាព។

ឯកឧត្តមបណ្ឌិតសភាចារ្យប្រធានអង្គប្រជុំ បានសម្រេចថាដាក់ក្រសួងទេសចរណ៍មួយមាត្រាបន្ថែម ចំពោះជំពូកទី៤ពាក់ព័ន្ធនឹងទណ្ឌកម្ម ឯកឧត្តមឯកភាព ឱ្យដាក់ការផាកពិន័យ ចំពោះការផាកពិន័យមុននឹងបញ្ជូនទៅរាជរដ្ឋាភិបាលគឺគេនឹងដាក់ឱ្យក្រសួងយុត្តិធម៌ពិនិត្យនិងពិចារណាសិន។ ឯកឧត្តមបានគូសបញ្ជាក់ថា ការប្រជុំនេះមិនមែនជាការសម្រេចចុងក្រោយទេ។ យើងនឹងកែលម្អហើយដាក់ចូលក្នុងក្រុមដូច្នេះសូមឯកឧត្តម លោកជំទាវផ្តល់នូវធាតុចូលបន្ថែមទៀតដែលចាំបាច់មុនយើងដាក់ជូនរដ្ឋាភិបាល ហើយខ្ញុំសូមស្នើសុំក្រុមការងារយកសារាចរផ្សេងៗ ដើម្បីបន្ថែមជាទម្ងន់ចូលខ្លឹមសារអនុក្រឹត្យនេះ ជាពិសេសគឺអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ហើយបញ្ហាប្រឈមដ៏សំខាន់ឥឡូវនេះយើងឃើញមានលក់នៅក្បែរសាលារៀន ប៉ុន្តែអាជ្ញាធរមូលដ្ឋានគាត់គ្មានសិទ្ធិដកហូតទេ ហេតុនេះប្រសិនបើចេញជាអនុក្រឹត្យហ្នឹងបាន យ៉ាងហោចណាស់ក៏មិនមានការចរាចរដោយចេញមុខដែរ ហើយបើយើងមិនដោះស្រាយទេអាចថា១០ឆ្នាំទៀតបញ្ហានេះអាចរីកធំជាងមុន វាអាចនឹងដូចរឿងគ្រឿងញៀនដែរ។ គ្រឿងញៀនពីមុនគ្រាន់តែចរាចរណ៍ឆ្លងកាត់ទេ ប៉ុន្តែឥឡូវនេះគឺទាំងផលិតក្នុងស្រុកទាំងការនាំចូលមកយ៉ាងច្រើន ដូច្នេះហើយបញ្ហានេះជាបញ្ហាធំមួយមិនមែនត្រឹមតែការប្រើប្រាស់បារីអេឡិចត្រូនិក អេបភី វេប ទេគឺការប្រើប្រាស់គ្រឿងញៀនក្រោមរូបភាពបារីអេឡិចត្រូនិក អេចភី វេប ហើយវានឹងរីកចូលក្នុងសាលារៀនខ្លាំងជាមិនខាន។

ការចេញវិធានការទប់ស្កាត់នេះ វាចាំបាច់កុំឱ្យគេថា "ទាល់តែគោបាត់ ទើបយើងធ្វើរបង"។

ជាចុងក្រោយឯកឧត្តមបណ្ឌិតសភាចារ្យប្រធានអង្គប្រជុំ សំណូមពរឯកឧត្តម លោកជំទាវ លោក លោកស្រី ជាពិសេសអាជ្ញាធរថ្នាក់មូលដ្ឋានទាំងអស់ចូលរួមបង្ក្រាបឱ្យបានទាន់ពេល។ ឯកឧត្តមជឿជាក់ថា ដូចអាជ្ញាធរប្រយុទ្ធប្រឆាំងគ្រឿងញៀនអនុវត្តអញ្ចឹងដែរ វាមិនងាយស្រួលទេ ទោះបីជាយើងឃាត់វាពីអាចេញមុខ វានឹងទៅជាអាលាក់មុខ កាន់តែពិបាកទៀត។ ប៉ុន្តែយ៉ាងហោចណាស់យើងអាចដោះស្រាយនៅជុំវិញសាលារៀន ដោយសារតែគ្រូៗពិបាកណាស់ គាត់អាចធ្វើការត្រួតពិនិត្យតែក្នុងសាលារៀនទេ ក្រៅរបងសាលារៀនគាត់ត្រួតពិនិត្យមិនបាន ហើយឥឡូវនេះយើងផ្តល់សិទ្ធិឱ្យគាត់។ ក្រសួងអប់រំ យុវជន និងកីឡានឹងចេញលិខិតមួយគឺនាយកសាលារៀនមានសិទ្ធិហាមឃាត់និងចូលរួមជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីហាមឃាត់ការលក់ដូរជុំវិញសាលារៀននិងហាមឃាត់ការប្រើប្រាស់ក្នុងសាលារៀន។

ជាទីបញ្ចប់ **ឯកឧត្តមបណ្ឌិតសភាចារ្យប្រធានអង្គប្រជុំ** សូមអរគុណចំពោះការសហការ ការយោគយល់ចំពោះចំណុចខ្វះខាតមួយចំនួនក្នុងការរៀបចំសេចក្តីព្រាងអនុក្រឹត្យនេះ។ ប្រសិនបើមានអ្វីសេសសល់ យើងនឹងបន្តកែលម្អ និងបន្ថែមធាតុចូលទៀតមុននឹងដាក់ជូនរាជរដ្ឋាភិបាល។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង១១ថ្ងៃត្រង់ នាថ្ងៃខែឆ្នាំដដែលប្រកបដោយស្មារតីភាតរភាព និងការទទួលខុសត្រូវខ្ពស់។

ថ្ងៃចន្ទ ១១រោច ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២៤

ប្រធានលេខាធិការដ្ឋានគ.អ.ស.ស.

បណ្ឌិត **សឿ សុជាតា**

បានឃើញនិងឯកភាព

ប្រធានគ.អ.ស.ស.

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**